ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៩ លេខ ៣ ខែកញ្ញា ២០១៥ តម្លៃ ១.៥០០៛

# ភាពគ្មានដីធ្លី និងពលកម្មកុមារនៅកម្ពុជា

## សេចក្ដីផ្ដើម

ពលកម្មកុមារ ឃើញមានច្រើនពាសពេញនៅកម្ពុជា ហើយនៅតែមានបន្តទៅទៀត៖ កុមារអាយុពី ៥ ទៅ ១៧ឆ្នាំ រហូតដល់ ៧៥៥.២៥០នាក់ (១៩% នៃកុមារសរុប) កំពុងបម្រើការងារ ក្នុងនោះ ៣០% បម្រើការងារមានគ្រោះថ្នាក់ ដូចជា ការជួញដូរផ្លូវភេទ ការជួញដូរថ្នាំញៀន ឬក៏ត្រូវគេជួញដូរ (NIS និង ILO 2013)។

ពលកម្មកុមារនៅកម្ពុជា ជាបញ្ហាចោទនៅទីជនបទ។ កុមារភាគច្រើនកំពុងបម្រើការងារ ដូចជា ការនេសាទ ចិញ្ចឹមសត្វ ដាំដំណាំ រកអុស និង ក្នុងលក្ខណៈជាអ្នកជួយក្រុមគ្រួសារដោយគ្មានប្រាក់កម្រៃ ហើយជួនកាលធ្វើជាពលករក្នុងវិស័យក្រៅផ្លូវការ ប៉ុន្តែមានតិចជាង ២% ដែលធ្វើការក្នុងរោងអាជីវកម្មខ្វះសុវត្ថិភាព និងផ្ដល់ប្រាក់កម្រៃទាប (NIS 2004, 11)។ ការប្រើពលកម្មកុមារ ជាការរកចំណូលបន្ថែម និងបំពេញកង្វះកម្លាំងពលកម្ម សម្រាប់គ្រួសារ មិនមែនសម្រាប់ជំនួសកម្លាំងពលកម្មពេញវ័យនោះទេ (Siddiqui 2012)។ ភាពគ្មានដីធ្លី ឬស្ទើរគ្មានដីធ្លី ជាមូលហេតុចម្បងមួយនៃភាពក្រីក្រនៅជនបទ៖ ការគ្មានដី ឬមានដីតូចពេកសម្រាប់ប្រើប្រាស់ វានាំឲ្យចំណូលគ្រួសារមានការខ្វះខាត។ ជាយុទ្ធសាស្ត្រដើម្បីដោះស្រាយជីវភាព សាមីគ្រួសារក៏បញ្ជូនកូនៗឲ្យទៅធ្វើការ។



ពលកម្មកុមារនៅកម្ពុជា ជាបញ្ហាចោទនៅទីជនបទ ខេត្តតាកែវ ឧសភា ២០១៥។

ចំណេះដឹងស្ដីពីទំនាក់ទំនងរវាង ភាពគ្មានដីធ្លី នឹងពលកម្មកុមារ នៅមានកម្រិតនៅឡើយ។ អត្ថបទនេះ ពិនិត្យពីកង្វះខាតទាំងឡាយក្នុងការសិក្សាកន្លងមក ដោយព្យាយាមឆ្លើយនឹងសំណួរដូចខាងក្រោម៖

១. តើភាពគ្មានដីធ្លី ជាប់ទាក់ទងយ៉ាងដូចម្ដេចទៅនឹង ពលកម្មកុមារ ?
២. តើស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច និងសុខុមាលភាពកុមារមានលក្ខណៈខុសគ្នាយ៉ាងណារវាងគ្រួសារគ្មានដីធ្លី និងគ្រួសារមានដីកាន់កាប់ ?
៣. តើក្មេងប្រុស និងក្មេងស្រី យល់យ៉ាងណាដែរពី តួនាទីរបស់ខ្លួនក្នុងការជួយផ្គត់ផ្គង់ជីវភាពគ្រួសារ ?

## និយមន័យពលកម្មកុមារ និងភាពគ្មានដីធ្លី

ពលកម្មកុមារ៖ ក្រសួងផែនការ (2012) ស្របតាមច្បាប់ស្ដីពីការងាររបស់ប្រទេសកម្ពុជា (អនុម័តនៅឆ្នាំ១៩៩៧) បានកំណត់និយមន័យ ពលកម្មកុមារ ថាជា ទម្រង់ណាមួយនៃសកម្មភាពសេដ្ឋកិច្ច ឬមិនមែនសេដ្ឋកិច្ច ចាប់ពី ១ម៉ោងក្នុងមួយសប្ដាហ៍ឡើងទៅ ដែលអាចធ្វើឲ្យខូចខាតដល់សុខភាព ឬការរីកលូតលាស់រាងកាយ សតិបញ្ញា ស្មារតី សីលធម៌ ឬស្ថានភាពក្នុង

## មាតិកា

ភាពគ្មានដីធ្លី និងពលកម្មកុមារនៅកម្ពុជា ........ ១
ការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយនៅជនបទកម្ពុជា ........ ៥
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១០
— ស្ថានភាពក្នុងប្រទេស ........ ១២
— សូចនាករ ........ ១៤
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........ ២០

អត្ថបទនេះប្រើប្រាស់លទ្ធផលបានពីការសិក្សារបស់ CDRI (Phann et al. 2014) មាននៅក្នុង www.ehs.unu.edu/file/get/9018។ សូមយោងអត្ថបទនេះថា Phann Dalis. 2015. “Landlessness and Child Labour in Cambodia.” *Cambodia Development Review* 19(3): 1-4. Phnom Penh: CDRI.

សង្គមរបស់កុមារ។ ច្បាប់ស្តីពីការងារ បានកំណត់អាយុធ្វើការទាបបំផុតត្រឹម ១៥ឆ្នាំ ប៉ុន្តែអនុញ្ញាតឲ្យកុមារអាយុពី ១២ ទៅ ១៤ឆ្នាំ ធ្វើការងារស្រាលៗបានរហូតដល់ ១៤ម៉ោងក្នុងមួយសប្តាហ៍។

តារាង១៖ ចំនួនម៉ោងធ្វើការក្នុងនិយមន័យពលកម្មកុមារ

| ក្រុមអាយុ | គ្មានគ្រោះថ្នាក់ | មានគ្រោះថ្នាក់ |
|---|---|---|
| ៥-១១ | ≥ ១ ម៉ោង/សប្តាហ៍ | |
| ១២-១៤ | ≥ ១៤ ម៉ោង/សប្តាហ៍ | សូម្បីតែ ≤ ១៤ ម៉ោង/សប្តាហ៍ |

សំគាល់៖ ការងារមានគ្រោះថ្នាក់ តាមនិយមន័យកំណត់ក្នុង (ILO 2002, 34) គឺ៖
- ការងារដែលធ្វើឲ្យកុមារ ត្រូវប៉ះជួបនឹងការបៀតបៀនរាងកាយ ផ្លូវចិត្ត ឬផ្លូវភេទ ឬក៏ រងការប៉ះពាល់ដោយកំដៅ កម្រិតសម្លេងរំខាន ឬរំញ័រ ដែលធ្វើឲ្យខូចសុខភាព
- ការងារនៅក្រោមដី ក្រោមទឹក នៅកន្លែងខ្ពស់អាចមានគ្រោះថ្នាក់ ឬក្នុងកន្លែងតូចចង្អៀត
- ការងារអនុវត្តជាមួយគ្រឿងចក្រ បរិក្ខារ និងឧបករណ៍ងាយបង្កគ្រោះថ្នាក់ ឬ ការងារលីសែងធ្ងន់ៗ ឬការងារច្រើនម៉ោងនៅពេលយប់។

ភាពគ្មានដីធ្លី៖ គ្រួសារគ្មានដី គឺគ្រួសារគ្មានដីកសិកម្ម ទោះដោយសារហេតុផលអ្វីក៏ដោយ។

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាបានប្រើទាំងវិធីសាស្ត្របែបបរិមាណ និងបែបគុណភាព រួមបញ្ចូលគ្នា។ វិធីសាស្ត្រស្រាវជ្រាវ បែបគុណភាព រួមមាន ការធ្វើសម្ភាសន៍ស៊ីជម្រៅដើម្បីប្រមូលព័ត៌មានលើប្រវត្តិ គំនិត និងបទពិសោធន៍របស់បុគ្គល និងកិច្ចពិភាក្សាតាមក្រុមស្នូលដើម្បីប្រមូលគំនិតឲ្យបានកាន់តែទូលំទូលាយ លើបញ្ហាគួរចាប់អារម្មណ៍។ ព័ត៌មានប្រមូលបានមិនតំណាងឲ្យគំនិតជារួមរបស់មនុស្សពេញវ័យ និងកុមារនៅកម្ពុជានោះទេ ប៉ុន្តែជាមតិរបស់អ្នកចូលរួមនានានៅតាមភូមិបានជ្រើសរើស។

ការវិភាគបែបបរិមាណ ផ្អែកលើទិន្នន័យបានពីអង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៤, ២០០៧, ២០០៩ និង ២០១១ ដែលតំណាងឲ្យទូទាំងប្រទេស។ ការវិភាគបែបគុណភាពផ្អែកជាសំខាន់លើ ការចុះសិក្សាដល់កន្លែងនៅតាមខេត្តពោធិ៍សាត់ ឧត្តរមានជ័យ ព្រះវិហារ ក្រចេះ កោះកុង ក្នុងឆ្នាំ២០១៤។ ក្រុមស្រាវជ្រាវបានជ្រើសយក ២ភូមិក្នុងខេត្តនីមួយៗ ហើយក្នុងភូមិនីមួយៗបានធ្វើការពិភាក្សាតាមក្រុមស្នូល ២, សម្ភាសន៍ស៊ីជម្រៅ ៣ និងសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ ១។ ដោយមានការពិគ្រោះយោបល់ជាមួយមេភូមិ ក្រុមស្រាវជ្រាវបានជ្រើសរើសសំណាកចេញពីគ្រួសារ ៤ប្រភេទ៖ ក្រីក្រមានដីកសិកម្ម, ក្រីក្រគ្មានដីកសិកម្ម, មិនក្រីក្រមានដីកសិកម្ម និងមិនក្រីក្រគ្មានដីកសិកម្ម។

## ភាពគ្មានដីធ្លី

ការសិក្សាបានស្វែងរកមូលហេតុនៃភាពគ្មានដីធ្លី ដោយផ្អែកលើអង្កេតមួយក្នុងឆ្នាំ២០១៤ លើចលករនៃភាពក្រីក្ររបស់ ១១៨៣គ្រួសារ ក្នុង ១១ភូមិ នៅតាមជនបទក្នុង ៩ខេត្ត មាន

តារាង២: ពលកម្មកុមារគិតតាមតំបន់ ឆ្នាំ២០០៤-១១

| | 2004 | 2007 | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|---|
| **កុមារអាយុពី ៥-១៤ឆ្នាំ** | **15603** | **4024** | **3632** | **12674** | **3348** | **3287** |
| ភ្នំពេញ | 1107 | 634 | 583 | 884 | 533 | 513 |
| ក្រុងដទៃទៀត | 2178 | 743 | 652 | 1286 | 579 | 599 |
| ជនបទ | 12318 | 2647 | 2397 | 10504 | 2236 | 2175 |
| ***ភាគរយនៃពលកម្មកុមារ*** | | | | | | |
| **ពលកម្មកុមារសរុប** | **21.8** | **23.3** | **21.1** | **25.1** | **18.6** | **18.7** |
| ភ្នំពេញ | 6.1 | 5.2 | 4.6 | 3.2 | 3.0 | 1.6 |
| ក្រុងដទៃទៀត | 15.8 | 14.3 | 14.4 | 11.0 | 9.0 | 9.0 |
| ជនបទ | 24.3 | 30.2 | 27.0 | 28.6 | 24.8 | 25.4 |

ប្រភព: CSES 2004-11

តារាង៣: វត្តមានពលកម្មកុមារ គិតតាមទំហំដីរបស់គ្រួសារធ្វើកសិកម្ម ឆ្នាំ២០០៤-១១ (%)

| | 2004 | 2007 | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|---|
| គ្រួសារគ្មានដី (ដី=0) | 18.9 | 20.0 | 17.1 | 19.1 | 18.3 | 20.7 |
| <1 ហិកតា | 25.9 | 29.7 | 26.4 | 29.0 | 24.7 | 23.9 |
| 1-2 ហិកតា | 29.6 | 34.6 | 33.0 | 34.1 | 25.4 | 30.1 |
| 2-3 ហិកតា | 30.3 | 39.4 | 26.8 | 29.6 | 31.0 | 28.4 |
| >3 ហិកតា | 28.9 | 33.3 | 35.7 | 32.5 | 25.1 | 28.2 |

ប្រភព: CSES 2004-11

បាត់ដំបង កំពង់ធំ ក្រចេះ កំពត កណ្ដាល ព្រៃវែង កំពង់ស្ពឺ ព្រះសីហនុ និង ព្រះវិហារ។ លទ្ធផលអង្កេតបង្ហាញថា គ្រួសារគ្មានដីធ្លីភាគច្រើនបំផុត មិនដែលមានដីធ្លីទេ។ មូលហេតុដទៃទៀត គឺការលក់ដី ការផ្ទេរដីឲ្យកូន ការផ្លាស់កន្លែង ការទន្ទ្រានយកដី ជាដើម។ គ្រួសារគ្មានដីកសិកម្មប្រមូលផ្ដុំភាគច្រើននៅតំបន់ទីក្រុង និងតំណាងឲ្យ ២៨% នៃគ្រួសារសរុបនៅចន្លោះឆ្នាំ២០០៤ និង ២០១១។ ពួកគេជាទូទៅប្រកបការងារក្នុងវិស័យសេវាកម្ម មានស្ថានភាពធូរធារជាងគ្រួសារមានដីកាន់កាប់ ហើយមេគ្រួសារតែងសម្រេចបានកម្រិតអប់រំខ្ពស់ជាង។

## វត្តមានពលកម្មកុមារ

ទិន្នន័យបានពី CSES (តារាង២) បង្ហាញថា ពលកម្មកុមារតែងឃើញមានច្រើនជាង ក្នុងគ្រួសារនៅតាមតំបន់ជនបទក្នុងអំឡុងឆ្នាំ២០០៤-១១។ ក្នុងពេលដែលចំណែកនៃពលកម្មកុមារនៅក្រុងភ្នំពេញ និងតំបន់ក្រុងផ្សេងទៀត បានធ្លាក់ចុះអស់ពាក់កណ្ដាលនោះ នៅតំបន់ជនបទវាកើនឡើង ២%។ ម្យ៉ាងទៀត កុមាររស់នៅក្នុងគ្រួសារគ្មានដីធ្លី មានដល់ ១៨% រីឯកុមាររស់នៅក្នុងគ្រួសារមានដីកាន់កាប់ មានត្រឹម ៩%។ ក្នុងចំណោមកុមារដែលធ្វើការ មានត្រឹម ១០% ប៉ុណ្ណោះដែលមិនបានចូលសាលាសោះ, មាន ៨០% ធ្វើការផង និងរៀនផង ហើយ ១០% ទៀតមិនមានចម្លើយបញ្ជាក់ទេ។

វត្តមានពលកម្មកុមារ ឃើញមានញឹកញាប់ជាងក្នុងគ្រួសារមានដីកាន់កាប់ ជាជាងគ្រួសារគ្មានដីធ្លី។ វត្តមានពលកម្មកុមារ វាមានទំនាក់ទំនងជាមួយទំហំដីកាន់កាប់ដែលប្រែប្រួលជុំវិញ កម្រិត ១៩% សម្រាប់គ្រួសារគ្មានដីធ្លី និង កម្រិតមធ្យម (mean) ៣០% (ចាប់ពី ២៤ ទៅ ៣៩%) សម្រាប់គ្រួសារមានដីកាន់កាប់ (តារាង ៣)។ នៅពេលបូកចូលនូវមុខរបរគ្រួសារទាំងអស់ ពលកម្មកុមារឃើញមានច្រើនជាងក្នុងគ្រួសារក្រីក្រ ជាជាងគ្រួសារធូរធារ។

## លទ្ធផលជាក់ស្ដែង

ការប៉ាន់ស្មានតាមម៉ូដែល Probit បង្ហាញថា កុមារក្នុងគ្រួសារគ្មានដីធ្លី មានចូលរួមក្នុងទីផ្សារពលកម្ម តិចជាង កុមារក្នុងគ្រួសារមានដីកាន់កាប់។ លទ្ធផលនេះស៊ីគ្នាជាមួយការសិក្សាពីមុនៗ (Mead 1997; Bhalotra and Heady 2000)។

វត្តមានពលកម្មកុមារ ជាប់ទាក់ទងគួរឲ្យកត់សំគាល់ទៅនឹងកម្រិតអប់រំរបស់មេគ្រួសារ៖ កុមារក្នុងគ្រួសារមានមេគ្រួបានបញ្ចប់យ៉ាងហោចណាស់ថ្នាក់បឋមសិក្សា មានឱកាសតិចជាងនឹងត្រូវបញ្ជូនឲ្យចេញទៅធ្វើការ។ ក្មេងប្រុសទំនងជាចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច ច្រើនជាងក្មេងស្រី។ កត្តារួមចំណែកផ្សេងទៀត មានជាអាទិ៍ ភាពពឹងផ្អែកច្រើនរបស់គ្រួសារទៅលើពលកម្មកុមារដើម្បីរស់រាន និងការរស់នៅក្នុងគ្រួសារធ្វើកសិកម្មនៅជនបទ។

ការប្រើម៉ូដែលដើម្បីប៉ាន់ស្មានពី អន្តរកម្មរវាងពលកម្មកុមារ និងទ្រព្យធនដី បង្ហាញថា គ្រួសារគ្មានដីធ្លីតែងឲ្យកូនចូលរួមក្នុងការងារ តិចជាង គ្រួសារមានដីកាន់កាប់ ទោះបីគាត់ក្រីក្រ ឬធូរធារក្ដី (រូបភាព១)។ ទោះជាយ៉ាងណាក៏ដោយ កុមារក្នុងគ្រួសារក្រីក្របំផុតគ្មានដី មានប្រូបាប៊ីលីតេខ្ពស់ជាង ក្នុងការត្រូវធ្វើការ បើធៀបនឹង កុមារក្នុងគ្រួសារធូរធារបំផុតគ្មានដី។

## លទ្ធផលរកឃើញបែបគុណភាព

មានការខុសប្លែកគ្នាមួយចំនួនរវាង កុមារក្នុងគ្រួសារគ្មានដីធ្លី និងកុមារក្នុងគ្រួសារមានដីកាន់កាប់។ កុមារក្នុងគ្រួសារគ្មានដីធ្លីតែងធ្វើការជាសំខាន់នៅក្នុងស្រែ និងចំការដំណាំលក់យកប្រាក់ ដើម្បីបានប្រាក់មកដោះស្រាយតម្រូវការចាំបាច់ ជាពិសេសអាហារ។ ពួកគេទទួលកាងារគ្រប់ប្រភេទ ឲ្យតែបានប្រាក់ឈ្នួលប្រចាំថ្ងៃ។ ឪពុកម្ដាយមានពេលតិចនៅមើលថែទាំកុមារ នៅពេលកុមារកំពុងត្រូវការពួកគាត់ខ្លាំងបំផុត។ កុមារត្រូវបាត់បង់ឱកាសបានទៅរៀនទៀងទាត់ ព្រោះគ្មានចំណីអាហារ, សម្ភារសិក្សាសមស្រប ឬមធ្យោបាយធ្វើដំណើរ។ អ្នកខ្លះត្រូវតាមឪពុកម្ដាយទៅធ្វើការនៅគ្រប់កន្លែង។

រូបភាព១: ពលកម្មកុមារក្នុងក្រុមបញ្ចភាគទ្រព្យធនដីទី១ (ឆ្វេង) និង ទី៥ (ស្ដាំ) នៅឆ្នាំ២០០៤-១១




Source: CSES 2004-11

កុមារក្នុងគ្រួសារមានដីកាន់កាប់ ជារឿយៗត្រូវធ្វើការក្នុងកសិដ្ឋានគ្រួសារ ឬក្នុងរបរជំនួញរបស់គ្រួសារ នៅពេលពួកគេមិនទៅសាលា។ ឪពុកម្តាយត្រួតពិនិត្យកុមារទាំងនេះយ៉ាងដិតដល់ និងមិនទុកឲ្យធ្វើការតែឯងទេ ហើយការងារធ្ងន់ៗគាត់ជួលពលករមកធ្វើ។ កុមារមានអាហារគ្រប់គ្រាន់ និងរបស់ចាំបាច់ដទៃទៀត ទោះបីពួកគេធ្វើការ ឬមិនធ្វើការក្តី។ អ្នកខ្លះរៀនចប់ថ្នាក់ទី១២ ឬថ្នាក់មហាវិទ្យាល័យ រីឯអ្នកខ្លះទៀតឈប់រៀន ហើយផ្តោតកម្លាំងក្នុងរបរជំនួញរបស់គ្រួសារ។

ឪពុកម្តាយ មនុស្សពេញវ័យ និងចាស់ទុំក្នុងគ្រួសារ មានឥទ្ធិពលខ្លាំងបំផុតទៅលើជីវិត និងសកម្មភាពសេដ្ឋកិច្ច របស់កុមារ។ក្មេងប្រុសដឹងថាត្រូវធ្វើតាមឪពុករបស់ខ្លួនដោយធ្វើការងារធ្ងន់ៗភាគច្រើន ដូចជា កាប់ឈើ និងឫស្សី គាស់ដំឡូង ភ្ជួររាស់ស្រែ ប្រមូលចំបើង ។ល។ ក្មេងស្រីទទួលការងាររបស់ម្តាយ ដែលគេចាត់ទុកជាការងារស្រាល ដូចជា មើលក្មេង ចិតដំឡូងហាល ស្ទូងជម្រះស្មៅ ប៉ាក់ខ្មែយ និងត្បាញកន្ទេល។ល។

## សេចក្តីសន្និដ្ឋាន

ភាពគ្មានដីធ្លី និងពលកម្មកុមារក្នុងគ្រួសារធ្វើកសិកម្ម មានទំនាក់ទំនងជាមួយគ្នា។ កុមារក្នុងគ្រួសារគ្មានដីធ្លីដែលត្រូវធ្វើការតែងមានតិចនាក់ជាង កុមារក្នុងគ្រួសារមានដីកាន់កាប់ដែលត្រូវធ្វើការ ព្រោះពួកគេមានឱកាសតិចជាង ដើម្បីធ្វើការងារតាមរដូវកាលនៅជនបទ និងខ្វះខាតធនធានដើម្បីទៅស្វែងរកការងារនៅកន្លែងផ្សេង។

កុមារក្នុងគ្រួសារក្រីក្រគ្មានដីធ្លី តែងមានចូលរួមធ្វើការងារច្រើននាក់ជាង កុមារក្នុងគ្រួសារធូធារគ្មានដីធ្លី។ កត្តាដែលជួយកាត់បន្ថយបញ្ហាពលកម្មកុមារ គឺកម្រិតអប់រំរបស់មេគ្រួសារ និងវត្តមានមនុស្សពេញវ័យច្រើនក្នុងគ្រួសារ។ ការរស់នៅក្នុងគ្រួសារធ្វើកសិកម្ម ការមានកុមារច្រើនអាយុ0-៤ឆ្នាំក្នុងគ្រួសារ និង ការរស់នៅក្នុងតំបន់ជនបទ គឺជា កត្តាសំខាន់ៗដែលរួមចំណែកធ្វើឲ្យមានពលកម្មកុមារ។

យោបល់មួយចំនួនដូចខាងក្រោម អាចជួយរំដោះកុមារពីភាពចាំបាច់ត្រូវធ្វើការ៖

- ជួយឲ្យគ្រួសារធ្វើកសិកម្ម កាន់តែមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាសំចៃពលកម្ម
- បំផុសឲ្យគ្រួសារយល់ពីសារៈសំខាន់នៃ ការអប់រំដែលមានតម្លៃយូរអង្វែង
- ដាក់បញ្ចូលជំនាញអនុវត្តជាក់ស្តែងទៅក្នុងប្រព័ន្ធអប់រំ
- ចាប់អនុវត្តកាលវិភាគអាចបត់បែនបាន នៅតាមសាលារៀន
- ផ្តល់សន្តិសុខស្បៀង ដល់ក្រុមគ្រួសាររបស់កុមារក្រីក្រតាមការកែលំអលទ្ធភាពមានដីដាំដុះ
- ពង្រឹងជំនាញបំពេញតួនាទីជាឪពុកម្តាយ
- ផ្តល់នូវសម្ភារសិក្សា ឯកសណ្ឋាន និង មធ្យោបាយធ្វើដំណើរ។

## ឯកសារយោង


Bhalotra, Sonia. 2000. *Is Child Work Necessary?* London: Suntory Centre.

Bhalotra, Sonia and Christopher Heady. 2000. *Child Farm Labour: Theory and Evidence.* London: Suntory Centre.

Bhalotra, Sonia and Christopher Heady. 2003. "Child Farm Labour: The Wealth Paradox." *World Bank Economic Review* 17(2): 197-227.

Emerson, M. Patric, and Andre Portela Souza. 2003. *Is There a Child Labour Trap? Intergenerational Persistence of Child Labour in Brazil.* Working Paper 02-W14. Nashville: Department of Economics, Vanderbilt University.

ILO (International Labour Organization). 2002. *Eliminating the Worst Forms of Child Labour: A Practical Guide to ILO Convention No. 182*. Handbook for Parliamentarians No. 3. Geneva: ILO.

Khan, Himayatullah. 2007. "Child Labour in Pakistan and Other Developing Countries." *RevistaTinerilorEconomisti* 1(8): 121-132.

Mead, Cain, T. 1977. "The Economic Activities of Children in a Village in Bangladesh." *Population and Development Review* 3(3): 201-227.

Ministry of Planning. 2012. "2012 Annual Progress Report." Phnom Penh: MOP.

NIS (National Institute of Statistics). "Cambodia Socio-Economic Survey (2004, 2007-2011)." Unpublished data.

NIS and ILO. 2013. *Cambodia Labour Force and Child Labour Survey 2012: Child Labour Report.* ILO International Programme on the Elimination of Child Labour. Phnom Penh: ILO.

Phann Dalis, Tong Kimsun, Phay Sokcheng and Pon Dorina. 2014. "Landlessness and Child Labour in Cambodia." Final Report. www.cdri.org.kh/Landlessness%20and%20Child%20Labour_CDRI_2015.pdf.

Siddiqui, A.B. 2012. "An Analytical Study of Child Labour—An Exploitation and Not Employment." *International Journal of Advanced Research in Management and Social Sciences* 1(3).

# ការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយនៅជនបទកម្ពុជា

## សាវតា

កម្ពុជាកន្លងមកមាន គ្រោះធម្មជាតិទាក់ទងនឹងធាតុអាកាសប៉ះពាល់ជាច្រើន ដូចជា ភ្លៀងធ្លាក់ខ្លាំង ទឹកជំនន់ ការរាំងស្ងួត និងព្យុះធំៗ ហើយការប្រែប្រួលអាកាសធាតុកំពុងធ្វើឲ្យបាតុភូតទាំងនេះកាន់តែខ្លាំងក្លាឡើង។ ប្រជាជនរស់នៅតំបន់ជនបទ ងាយរងគ្រោះជាងគេពីវិបត្តិទាំងនេះ ព្រោះមានសមត្ថភាពតិច ក្នុងការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ និងមហន្តរាយនានា។ ក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយភាពងាយរងគ្រោះ និងបង្កើនភាពធន់នឹងមហន្តរាយ រដ្ឋាភិបាលបានបង្កើតយន្តការជាច្រើនសម្រាប់គ្រប់គ្រងគ្រោះអាសន្ន និងជួយដល់សហគមន៍រងគ្រោះក្នុងការទប់ទល់នឹងមហន្តរាយ និងស្តារជីវភាពឡើងវិញ។

នៅឆ្នាំ១៩៩៥ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (គជគម-NCDM) បានកកើតឡើង ហើយមានទំនួលខុសត្រូវរួមលើការកសាង និងសម្របសម្រួលវិធានការឆ្លើយតប និងផែនការសង្គ្រោះបន្ទាន់។ ស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយ ដូចជា គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (គគមខ-PDMC) គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក (គគមស-DCDM) គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ (គគមឃ-CCDM) និង ក្រុមគ្រប់គ្រងគ្រោះមហន្តរាយភូមិ (កគមភ-VDMG) ទទួលបន្ទុកធ្វើផែនការគ្រប់គ្រងមហន្តរាយនៅតាមកម្រិតរៀងៗខ្លួន ដោយមានជំនួយទ្រទ្រង់ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការមិនមែនរដ្ឋាភិបាល (NGOs) និង គជគម។ នៅកម្រិតភូមិ និងឃុំ មានផែនការសកម្មភាពពីរប្រភេទ គឺមួយសម្រាប់ការត្រៀមរៀបចំ និងឆ្លើយតបនឹងគ្រោះអាសន្ន ហើយមួយទៀតសម្រាប់ការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ។

អត្ថបទនេះ ពណ៌នាពីដំណើរការធ្វើផែនការនៅកម្រិតភូមិ និងឃុំ ដើម្បីគ្រប់គ្រងគ្រោះមហន្តរាយនៅជនបទកម្ពុជា។ អ្នកស្រាវជ្រាវប្រើប្រាស់ព័ត៌មានបានពី លទ្ធផលបឋមនៃការសិក្សាមួយ (Sam 2015) ដែលធ្វើឡើងដើម្បីកំណត់ពី ១) ស្ថានភាពបណ្តាគម្រោងគ្រប់គ្រងគ្រោះមហន្តរាយផ្អែកលើសហគមន៍ និងទទួលជំនួយពី NGO និង ២) មធ្យោបាយប្រសើរបំផុតដើម្បីជំរុញការត្រៀមរៀបចំ និងការធ្វើផែនការសង្គ្រោះបន្ទាន់ប្រកបដោយប្រសិទ្ធភាពនៅតាមសហគមន៍ជនបទ។ ការសិក្សានេះ ខាងវិទ្យាស្ថានជប៉ុនសម្រាប់ការស្រោចស្រព និងដោះទឹក បានចុះកិច្ចសន្យាឲ្យអនុវត្ត។



## វិធីសាស្ត្រ

ទិន្នន័យបឋមប្រមូលបានពី ការពិភាក្សាតាមក្រុមស្នូលចំនួន ៤ ដែលបានធ្វើឡើងជាមួយសមាជិក គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុកស្រីស្នំ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំត្រាំសសរ ក្នុងខេត្តសៀមរាប និងសមាជិកគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយសង្កាត់លលកស និងឃុំកំពង់ពោធិ៍ ក្នុងខេត្តពោធិ៍សាត់។

ព័ត៌មានបន្ថែម ប្រមូលបានពីសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ ចំនួន ៧ ធ្វើឡើងជាមួយតំណាងមកពី គជគម អង្គការភ្លែនអន្តរជាតិកម្ពុជា, អង្គការ Action Aid អង្គការជីវិតថ្លៃថ្នូរ អង្គការ Dan Church Aid/Christian Aid អង្គការ Oxfam GB និងអង្គការដៃគូសម្រាប់ការអភិវឌ្ឍកម្ពុជា។

ទិន្នន័យប្រភពទី២ ប្រមូលបានពី គជគម និង NGOs ក្នុងតំបន់ ដែលបានចូលរួមក្នុងការគ្រប់គ្រងគ្រោះអាសន្ន និងផ្តោតលើការផ្តល់ការបណ្តុះបណ្តាលពីការគ្រប់គ្រងមហន្តរាយ។

## លទ្ធផលសិក្សា

### រចនាសម្ព័ន្ធ និងមុខងាររនៃ គគមឃ និង កគមភ

អនុក្រឹត្យលេខ៦១ ចុះថ្ងៃទី២៩ មិថុនា ២០០៦ បានអនុញ្ញាតឲ្យបង្កើត គគមឃ ហើយសេចក្តីណែនាំ លេខ៣១៥ ចុះថ្ងៃទី២១ កក្កដា ២០១០ បាននាំឲ្យមានការបង្កើត កគមភ។ ដូចមានបង្ហាញក្នុងរូបភាព១ គគមឃ ចែកចេញជា ៣ក្រុមដែលអនុវត្តការងារក្នុងតំបន់បីចម្បងៗ ហើយ កគមភ ចែកចេញជា ៤ក្រុម។ សមាជិកក្រុម និងគណៈកម្មាធិការទាំងអស់ ជាអ្នកស្ម័គ្រចិត្ត។ ប្រសិនបើមានជំនួយទ្រទ្រង់ពី NGO ពួកគេទទួលបានថវិកាខ្លះ បូកនិងសោហ៊ុយធ្វើដំណើរ អំពីអាជ្ញាធរឃុំរៀងៗខ្លួន។

គគមឃ មានភារកិច្ចចម្បងកសាងផែនការដើម្បីកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ, ត្រៀមរៀបចំនិងចាត់វិធានការ

---

អត្ថបទនេះ រៀបចំដោយ សំ ស្រីមុំ អ្នកស្រាវជ្រាវផ្នែកបរិស្ថាន។ សូមយោងអត្ថបទនេះថា Sam Sreymom. 2015. “Disaster Management Planning in Rural Cambodia.” *Cambodia Development Review* 19(3): 5-9. Phnom Penh: CDRI.

សង្គ្រោះបន្ទាន់, អនុវត្តសកម្មភាពមានចែងលំអិតក្នុងផែនការទាំងពីរ, សម្របសម្រួលការគ្រប់គ្រងហានិភ័យមានគ្រោះមហន្តរាយនៅកម្រិតស្រុកនិងភូមិ និងសកម្មភាពសង្គ្រោះបន្ទាន់, និងអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយគ្រប់គ្រងមហន្តរាយ។ កគមភ មានតួនាទីចម្បង ពង្រឹងអនុវត្តន៍យន្តការត្រៀមរៀបចំទប់ទល់គ្រោះមហន្តរាយ តាមការចែករំលែកព័ត៌មានស្តីពីគ្រោះមហន្តរាយដល់ប្រជាជនក្នុងមូលដ្ឋាន, ផ្សព្វផ្សាយការប្រកាសអាសន្នពីការគំរាមកំហែងបម្រុងកើតមាន និងជួយជំលៀសប្រជាជន និងសត្វចិញ្ចឹមក្នុងពេលមានគ្រោះអាសន្ន។

គគមឃ ទទួលបន្ទុកធ្វើផែនការត្រៀមទប់ទល់សម្រាប់ឃុំ ហើយ កគមភ ទទួលបន្ទុកធ្វើផែនការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយក្នុងមូលដ្ឋាន។ ស្ថាប័នទាំងពីរទទួលជំនួយទ្រទ្រង់ពី នាយកដ្ឋានជំនាញរបស់ គជគម, គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក និងខេត្ត, NGOs ក្នុងស្រុក និងដៃគូអភិវឌ្ឍន៍។

អង្គការមិនមែនរដ្ឋាភិបាលដែលជួយទ្រទ្រង់នានា អនុវត្តតាមសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ មានចែងក្នុងគោលការណ៍ណែនាំផ្នែកបច្ចេកទេសសម្រាប់ការធ្វើផែនការត្រៀម និងសង្គ្រោះបន្ទាន់ (NCDM 2013b) ព្រមទាំងផ្តល់ការបណ្តុះបណ្តាលមុនពេលធ្វើផែនការ ទៅដល់សមាជិក គគមឃ និង កគមភ ។ ការបណ្តុះបណ្តាលគ្របដណ្តប់លើប្រធានបទដូចខាងក្រោម៖

រូបភាព១៖ រចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ




ប្រភព៖Consortium AAC/DAC/PIN/Oxfam/SCI 2014; Leng 2014; NCDM 2013a; Khna Sanday CCDM 2013; Lolok Sa CCDM 2014

- ការប្រមូលទិន្នន័យ
- ការកសាងផែនការ
- មហន្តរាយ និងការគ្រប់គ្រង ហើយនិង គោលគំនិតជាមូលដ្ឋានស្តីពីការងើបឡើងវិញ
- យន្តការ រចនាសម្ព័ន្ធ កាតព្វកិច្ច និងតួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងមូលដ្ឋាន
- ការធ្វើផែនទីបង្ហាញពីអ្នកពាក់ព័ន្ធ
- បទពិសោធន៍រៀនសូត្របានពី ការគ្រប់គ្រងគ្រោះមហន្តរាយ
- ផលប៉ះពាល់នៃគ្រោះមហន្តរាយទៅលើ ស្ត្រី កុមារ និងក្រុមងាយរងគ្រោះដទៃទៀត
- ការវិភាគលើក្រុមងាយរងគ្រោះ
- ការធ្វើផែនទីបង្ហាញគ្រោះអន្តរាយ សម្រាប់កម្រិតធ្វើផែនការ ឬខ្នាតសមស្របណាមួយ
- សេណារីយ៉ូមានហានិភ័យ និងកម្រិតហានិភ័យ
- ការត្រៀមរៀបចំសង្គ្រោះបន្ទាន់ និងការធ្វើផែនការឆ្លើយតប
- របៀបកំណត់ធនធានមូលដ្ឋាន។

ការបណ្តុះបណ្តាលពីការប្រមូលទិន្នន័យ គ្របដណ្តប់លើរបៀបប្រមូលព័ត៌មានបឋមស្តីពីបញ្ហានានា ការលំបាកផ្សេងៗដែលប្រជាជនងាយរងគ្រោះត្រូវប្រឈមមុខ និងសមត្ថភាពរបស់ពួកគេក្នុងការដោះស្រាយបញ្ហាទាំងនោះ (NCDM 2013a, c)។

## ការកសាងផែនការត្រៀមរៀបចំសង្គ្រោះបន្ទាន់ និងឆ្លើយតប

គជគម (2013b) បានចងក្រងគោលការណែនាំផ្នែកបច្ចេកទេសស្តីពី ការធ្វើផែនការត្រៀម និងគ្រប់គ្រងគ្រោះហានិភ័យ នៅកម្រិត ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ប៉ុន្តែមិនមែននៅកម្រិតឃុំទេ។ ដោយសារមិនមានគោលការណ៍ណែនាំជាក់លាក់នោះ ទើបផែនការឃុំត្រូវបានកសាងឡើង តាមរបៀបដូចគ្នានឹងផែនការនៅកម្រិតស្រុក និងខ័ណ្ឌដែរ (រូបភាព២)។

ការធ្វើផែនការដោយមានការចូលរួម ត្រូវមានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ ជាពិសេស NGOs ផ្តល់ជំនួយទ្រទ្រង់ និងគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក និងឃុំ។ ស្របតាមគោលការណ៍ណែនាំផ្នែកបច្ចេកទេសរបស់ គជគម សមាជិកគណៈកម្មាធិការ ត្រូវចូលរួមក្នុងការបណ្តុះបណ្តាលលើប្រធានបទជាច្រើន មុនពេលអាចចាប់ផ្តើមដំណើរការធ្វើផែនការ។ ទោះយ៉ាងនេះក្តី ខ្លឹមសារនៃផែនការត្រៀមរៀបចំសង្គ្រោះបន្ទាន់ និងឆ្លើយតប (EPRP) អាចប្រែប្រួលខុសគ្នាបន្តិចបន្តួចពី ការណែនាំរបស់ គជគម អាស្រ័យលើ NGO ដែលផ្តល់ជំនួយទ្រទ្រង់។ ផែនការទាំងនោះ ផ្តោតជាសំខាន់លើ ការត្រៀមរៀបចំនិងការឆ្លើយតបរបស់ស្ថាប័ន ធនធានដែលពួកគេត្រូវការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

រូបភាព២៖ ការកសាងផែនការត្រៀមរៀបចំសង្គ្រោះបន្ទាន់ និងឆ្លើយតបនៅកម្រិតឃុំ




ប្រភព៖ សម្ភាសន៍ ក្នុងឆ្នាំ២០១៤; NCDM 2013c

រូបភាព៣៖ ការបង្កើតផែនការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ




សំគាល់៖ *អ្នកពាក់ព័ន្ធ រួមមាន សហគមន៍មូលដ្ឋាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ និងស្រុក និង NGOs ផ្តល់ជំនួយទ្រទ្រង់

ប្រភព៖ Consortium AAC/DAC/PIN/Oxfam/SCI 2014

## ការកសាងផែនការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ

ផែនការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ (DRRPs) មិនមាននៅក្នុងឃុំសិក្សាទាំងបីទេ។ ប៉ុន្តែ តំណាងមកពីអង្គការជីវិតថ្លៃថ្នូរ បានប្រាប់ថា ផែនការប្រភេទនេះកន្លងមកមានបង្កើតនៅក្នុងភូមិ និងឃុំគោលដៅរបស់គម្រោង ហើយនៅទីនោះគេតែងហៅថា ផែនការគ្រប់គ្រងហានិភ័យមានគ្រោះមហន្តរាយ ឬផែនការអភិវឌ្ឍន៍ឃុំ។

DRRP កើតចេញពី ដំណើរការកំណត់តម្រូវការគ្រប់គ្រងហានិភ័យមានគ្រោះមហន្តរាយ និងការកំណត់អាទិភាពគម្រោងអភិវឌ្ឍន៍នានានៅក្នុងមូលដ្ឋាន។ មុនពេលបង្កើត កគមភ សកម្មភាពទាំងនេះ មានប្រធានភូមិទទួលខុសត្រូវជាសំខាន់ ដោយមានជំនួយទ្រទ្រង់ពីក្រុមប្រឹក្សាឃុំ។ បន្ទាប់ពីកំណត់ឃើញ ហើយ ក្រុមប្រឹក្សាឃុំត្រូវពិនិត្យជ្រើសរើសបញ្ហា និងតម្រូវការជាអាទិភាព ហើយដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងផែនការវិនិយោគឃុំ។ តាមនេះ នៅពេលក្រោយៗមកទៀត ការកាត់បន្ថយហានិភ័យមានគ្រោះមហន្តរាយ ក៏ត្រូវបានដាក់បញ្ចូលទៅក្នុងការធ្វើផែនការឃុំ។

ដោយមានជំនួយទ្រទ្រង់ពី NGOs នោះ ក៏មានការបង្កើតដាច់ដោយឡែកពីគ្នានូវ EPRPs និង DRRPs របស់ឃុំ។ DRRPs មានភាពខុសប្លែកពី ផែនការណែនាំដោយ គជគម និងផ្តល់គំនិតដោយ NGOs ដែលជួយទ្រទ្រង់។ គជគម ណែនាំថា DRRPs គប្បីមានទម្រង់ជាតារាងរាយមុខសកម្មភាព រីឯ NGOs ដែលផ្តល់ជំនួយ ចង់បានជារបាយការណ៍មានរៀបរាប់ពី ស្ថានភាពគ្រោះមហន្តរាយ ការវាយតម្លៃហានិភ័យ ព័ត៌មានពីស្ថាប័នមូលដ្ឋានសំខាន់ៗ និងផែនការត្រៀមរៀបចំ។ DRRPs របស់ភូមិ និងឃុំត្រូវពិនិត្យឡើងវិញរៀងរាល់ ២ ទៅ ៣ឆ្នាំម្តង។

## បញ្ហាប្រឈម

បញ្ហាប្រឈមចម្បងមួយដល់ការកសាងផែនការភូមិ និងឃុំសម្រាប់ការត្រៀមរៀបចំសង្គ្រោះបន្ទាន់ ការឆ្លើយតប និងការងើបឡើងវិញ គឺចំណេះដឹងតិចនៅក្នុងមូលដ្ឋានស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ដែលបណ្តាលជាសំខាន់មកពី ភាពស្មុគស្មាញនៃការវាយតម្លៃហានិភ័យ និងសកម្មភាពធ្វើផែនការ កម្រិតអប់រំទាបក្នុងចំណោមប្រជាជនមូលដ្ឋាន និងពេលវេលាមានតិចសម្រាប់ការបណ្តុះបណ្តាល ទោះបីជាកន្លងមកការបណ្តុះបណ្តាលមានផ្តល់យ៉ាងទូលំទូលាយនៅក្នុងដំណើរការអនុវត្តគម្រោងក្តី។

បញ្ហាមួយទៀតដែលប៉ះពាល់ដល់ ការកសាងផែនការគ្រប់គ្រងគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព គឺកង្វះពេលវេលា និងទីកន្លែង។ ការធ្វើផែនការដោយមានការចូលរួម តាមធម្មតាត្រូវមានមនុស្សច្រើនចូលរួម ប៉ុន្តែតម្រូវការ និងសំពាធក្នុងការរកចិញ្ចឹមជីវិតប្រចាំថ្ងៃ ធ្វើឲ្យគណៈកម្មាធិការ និងសមាជិកក្រុម មិនអាចមានកម្លាំង និងពេលគ្រប់គ្រាន់ មកចូលរួមឲ្យបានពេញលេញនៅក្នុងគំនិតផ្តួចផ្តើមផ្សេងៗក្នុងមូលដ្ឋានទេ។ តួយ៉ាង ការប្រមូលព័ត៌មានឲ្យគ្រប់គ្រាន់ ដើម្បីវាយតម្លៃពីហានិភ័យ និងកសាងផែនការសកម្មភាពមួយឡើង ត្រូវមានការចូលរួមពីសំណាក់ប្រជាជនមូលដ្ឋាន។ ប៉ុន្តែលទ្ធភាពក្នុងការប្រមូលទិន្នន័យ គឺមានតិច ព្រោះប្រជាជនត្រូវផ្តោតការប្រឹងប្រែង ក្នុងការរកចំណូលចិញ្ចឹមជីវិត។

ប្រសិនបើគ្មានការទទួលស្គាល់ និងដោះស្រាយឧបសគ្គទាំងនេះឲ្យបានសមស្របទេ ការបង្កើតគំនិតថ្មី និងការធ្វើផែនការអាចបង្កបរាជ័យដោយខ្លួនឯង៖ សមត្ថភាពសម្រាប់ការចូលរួមសកម្ម គ្មានការរីកចម្រើន ឬដើរមិនទាន់ការបង្កើតគំនិតថ្មីខាងបច្ចេកវិទ្យា បុគ្គលនានា និងសហគមន៍ មិនដឹងពីវិធីសម្រាប់ជួយកាត់បន្ថយការគម្រាមកំហែងដោយអាកាសធាតុ និងគ្រោះមហន្តរាយ ព្រមទាំងផលប៉ះពាល់ពាក់ព័ន្ធផ្សេងៗ, ការមានអារម្មណ៍ថាខ្លួនគ្មានសិទ្ធិអំណាច ឬការគិតថាកិច្ចប្រឹងប្រែងរបស់

ខ្លួនមិនអាចផ្លាស់ប្ដូរអ្វីបាន ទាំងអស់នេះនាំឲ្យមានការស្ពឹកស្រពន់ និងការទទួលយកស្ថានភាពសព្វថ្ងៃ។ ចំណុចនេះអាចមើលឃើញខ្លះដែរក្នុងកិច្ចពិភាក្សាជាមួយសមាជិក DMCC និង គគមឃ ហើយការសាកសួរពីបញ្ហាដែលពួកគេត្រូវប្រឈម បានផ្ដល់នូវគំនិតតិចតួចណាស់។

ចីរភាពនៃជំនួយសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ និងការងើបឡើងវិញ ក៏មានគូសបញ្ជាក់ដែរ។ អ្នកចូលរួមពិភាក្សា និងអ្នកឆ្លើយសម្ភាសន៍ បានសង្កត់ធ្ងន់ពីការចាំបាច់ត្រូវបន្តជំនួយទ្រទ្រង់ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ។ មូលនិធិមានតិចសម្រាប់សកម្មភាពគ្រប់គ្រង និងឆ្លើយតបនឹងគ្រោះអាសន្ន ក៏ដូចជាកង្វះការចូលរួមពីសហគមន៍ ក្នុងកិច្ចប្រឹងប្រែងគ្រប់គ្រងគ្រោះមហន្តរាយ បានរាំងដល់ការអនុវត្តផែនការឆ្លើយតបនឹងគ្រោះអាសន្ន និងកាត់បន្ថយគ្រោះមហន្តរាយនៅកម្រិតមូលដ្ឋាន។

បញ្ហាមានមូលនិធិតិចដែលរាំងដល់ការកសាង និងអនុវត្តផែនការ មានលើកឡើងនៅក្នុងឃុំសិក្សាទាំងបី និងដោយតំណាង NGO។ ការចូលរួមសកម្មពីសំណាក់ប្រជាជនមូលដ្ឋាន សំខាន់ខ្លាំងណាស់ ក្នុងការគ្រប់គ្រងហានិភ័យមានគ្រោះមហន្តរាយ។ ប្រជាជនមូលដ្ឋានត្រូវធ្វើសហប្រតិបត្តិការជាមួយ កគមភ និង គគមឃ នៅមុនពេល ក្នុងពេល និងនៅក្រោយពេលមានគ្រោះមហន្តរាយ។ ប៉ុន្តែការពិភាក្សា និងសម្ភាសន៍ជាច្រើនបានបញ្ជាក់យ៉ាងច្បាស់ថា ប្រជាជនខ្លះមិនអើពើនឹងការដាស់តឿនឲ្យប្រុងប្រយ័ត្នពីសំណាក់ កគមភ និង គគមឃ ទេ។ ផ្ទុយទៅវិញ ពួកគេតែងចាំដល់ពេលមានគ្រោះមហន្តរាយកើតឡើង ទើបធ្វើសកម្មភាព ហើយតាមនេះ ក៏ធ្វើឲ្យថយចុះប្រសិទ្ធភាពនៃផែនការសង្គ្រោះបន្ទាន់ និងសកម្មភាពឆ្លើយតប។

## សេចក្ដីសន្និដ្ឋាន និងការផ្ដល់មតិ

ទោះបីមានការពិគ្រោះយោបល់ និងការបណ្ដុះបណ្ដាលយ៉ាងទូលំទូលាយក៏ដោយ ក៏ការចូលរួមជាក់ស្ដែងរបស់ប្រជាជនមូលដ្ឋាន ក្នុងការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយ នៅមានកម្រិតទាប។ ចំណុចនេះបង្ហាញច្បាស់ពីតម្រូវការបន្ទាន់នូវ ជំនួយទ្រទ្រង់ជាបន្តពីសំណាក់ស្ថាប័នជំនាញ និង NGOs ដល់គ្រប់ដំណាក់កាលនៃការធ្វើផែនការ និងការអនុវត្ត។

ការធ្វើផែនការឃុំ មិនមែនជាការងារថ្មីទេសម្រាប់អាជ្ញាធរភូមិឃុំដែលមានបទពិសោធន៍ក្នុងការវាយតម្លៃពីតម្រូវការ និងអាទិភាពក្នុងមូលដ្ឋាន និង ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ និងផែនការវិនិយោគ។ ទោះជាយ៉ាងនេះក្ដី ការត្រៀមរៀបចំសង្គ្រោះបន្ទាន់ ការឆ្លើយតប និងការងើបឡើងវិញ បានជួបឧបសគ្គដោយសារអាជ្ញាធរមូលដ្ឋានមានសមត្ថភាពតិច ក្នុងការវាយតម្លៃលើហានិភ័យស្មុគស្មាញ និងក្នុងសកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយ, ឧបសគ្គទាក់ទងនឹងការចូលរួមនៅមូលដ្ឋាន ក្នុងការប្រមូលទិន្នន័យ, និងការពិបាកបំផុសឲ្យសហគមន៍ចូលរួមធ្វើសហប្រតិបត្តិការក្នុងពេលមានគ្រោះមហន្តរាយ។

មតិយោបល់ខាងក្រោមនេះ អាចជួយបំបាត់ឧបសគ្គរាំងការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយ ដែលបានកំណត់ឃើញក្នុងការសិក្សានេះ៖

- ពង្រីកការយល់ដឹង និងសមត្ថភាពរបស់សមាជិក គគមឃ និង កគមភ តាមរយៈ ការធ្វើឲ្យការវាយតម្លៃពីហានិភ័យ និងសកម្មភាពធ្វើផែនការ មានលក្ខណៈងាយស្រួលជាងមុន និងការផ្ដល់ការបណ្ដុះបណ្ដាលជាបន្តបន្ទាប់កាន់តែច្រើនឡើង។
- លើកកម្ពស់ការចូលរួមដ៏មានន័យពីសំណាក់សហគមន៍ តាមរយៈការជំរុញឲ្យសមាជិក គគមឃ និង កគមភ ចែករំលែកព័ត៌មានស្ដីពីគ្រោះមហន្តរាយ។
- ញ៉ាំងឲ្យការធ្វើផែនការ និងការអនុវត្តមានចីរភាពល្អតាមរយៈការធានាឲ្យមានជំនួយទ្រទ្រង់ផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីស្ថាប័នជំនាញ និង NGOs ។
- បណ្ដុះបណ្ដាលសមាជិក គគមឃ និង កគមភ ពីរបៀបសរសេរសំណើដើម្បីស្វែងរកមូលនិធិពី NGOs និងអ្នកផ្ដល់ជំនួយដទៃទៀត។
- ប្រមែប្រមូលការដឹកនាំ គំនិត និងកិច្ចប្រឹងប្រែងនៅក្នុងមូលដ្ឋាន ក្នុងអំឡុងពេលទាំងមូលនៃការអនុវត្តផែនការសកម្មភាពសហគមន៍។

## ឯកសារយោង


Consortium AAC/DAC/PIN/Oxfam/SCI. 2014. “Training of Trainers on Community Based Disaster Risk Reduction.” Phnom Penh: DIPECHO IX.

Direction No. 315. 2010. Establishment of the Village Group for Disaster Management. Phnom Penh: NCDM.

Khna Sanday Commune Disaster Management Committee. 2013. Contingency Plan for Flood. Siem Reap: Plan International. (Unpublished, available at the commune office).

Leng Heng An. 2014. “Collaboration in Disaster Risk Reduction (DRR) between the National Committee for Disaster Management and Non-Government Organizations (NGOs).” Accessed 2 March 2015, www.adrc.asia/aboutus/vrdata/finalpresentation/2013B_KHM _frp.pdf.

Lolok Sa Commune Disaster Management Committee. 2014. Contingency Plan to Disasters. (Unpublished, available at the commune office).

NCDM (National Committee for Disaster Management). 2013a. Guide Book for Trainer: Disaster Risk Management for Disaster Committee at Municipality, Province, District and Khan. Phnom Penh: NCDM.

NCDM. 2013b. Technical Guidance on Disasters and Contingency Plan Development at Municipality, Province, District and Khan. Phnom Penh: NCDM.

NCDM. 2013c. Training Document on Disasters and Contingency Plan Development. Phnom Penh: NCDM.

Sam Sreymom. 2015. “Community-Based Disaster Management Plan in Cambodia.” A report to the Japanese Institute of Irrigation and Drainage. Unpublished.

Sub-decree No. 61. 2006. Establishment of Commune Committee for Disaster Management in Cambodia. Phnom Penh: Royal Government of Cambodia.

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ ពណ៌នាពីសូចនាករសេដ្ឋកិច្ច នៅប្រទេសធំៗមួយចំនួន និងនៅអាស៊ីអាគ្នេយ៍។

នៅត្រីមាសទី២ ផសស ពិត នៅ ឥណ្ឌូនេស៊ី កើន ៤,៧% ធៀបនឹងឆ្នាំមុន ដែលជាកំណើនទាបបំផុត នៅត្រីមាសទី២ គិតចាប់ពីឆ្នាំ២០១០ មក។ កំណើននៅម៉ាឡេស៊ី មានកម្រិត ៤,៩% ខ្ពស់ជាងឆ្នាំមុន ប៉ុន្តែកំណើន ផសស ពិតប្រចាំឆ្នាំ ធ្លាក់ចុះ ០,៧ ឯកតាភាគរយ ធៀបត្រីមាសមុន។ ថ្លៃទំនិញ និង តម្រូវការក្នុងស្រុកទាបជាងមុន បានរួមចំណែកបញ្ចុះកំណើន។ កំណើន ផសស ពិត នៅសិង្ហបុរី ធ្លាក់មកត្រឹម ១,៨% ធៀបឆ្នាំមុន និងទាបជាងកម្រិត ២,៦% កាលពីត្រីមាសមុន។ កំណើនពីមួយឆ្នាំទៅមួយឆ្នាំនៅថៃ ឡើងដល់ ២,២% នៅត្រីមាសទី២ ធៀបនឹង ០,៣% កាលពីឆ្នាំមុន។ វិនិយោគសាធារណៈ និងទេសចរណ៍ចូលរួមចំណែកចម្បងនៅក្នុងកំណើននេះ។ កំណើន ផសស ពិតពីមួយឆ្នាំទៅមួយឆ្នាំ នៅវៀតណាម ឡើងដល់ ៦,៥%។

កំណើន ផសស នៅចិន និងហុងកុង ធ្លាក់ចុះបន្តិចមកត្រឹម ៧,០% និង ២,៨% រៀងគ្នា ក្នុងត្រីមាសទី២។ កំណើននៅកូរ៉េខាងត្បូង ធ្លាក់មកត្រឹម ២,២% ហើយនៅតៃវ៉ាន់ ធ្លាក់មកត្រឹម ០,៥%។ ការធ្លាក់ចុះអត្រាកំណើននៅតៃវ៉ាន់ បណ្ដាលជាចម្បងមកពីការធ្លាក់ចុះការនាំចេញ។

នៅត្រីមាសទី២ កំណើន ផសស នៅសហភាពអឺរ៉ុប ឡើងដល់ ១,២% ធៀបនឹង ០,៧% កាលពីឆ្នាំមុន។ ផសស ពិត នៅជប៉ុន កើន ០,៧% ធៀបឆ្នាំមុន។ នៅត្រីមាសនេះ សេដ្ឋកិច្ចជប៉ុនអាចបញ្ចប់ការរួមចុះ ហើយត្រឡប់ជាមានកំណើនវិញ ដោយសារប្រាក់យ៉េនធ្លាក់ថ្លៃ ប៉ុន្តែដំណើរបែបនេះមិនមែនជា ដំណោះស្រាយសម្រាប់ ការងើបសេដ្ឋកិច្ចឡើងវិញក្នុងរយៈពេលវែងនោះទេ។ កំណើន ផសស ពិត នៅសហរដ្ឋអាមេរិក ធ្លាក់ចុះបន្តិច មកត្រឹម ២,៣% ធៀបនឹង ២,៦% កាលពីឆ្នាំមុន។ កំណើននេះជំរុញឡើងដោយវិស័យសេវាកម្ម ជាពិសេស ការថែទាំសុខភាព និងការដឹកជញ្ជូន។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់

អតិផរណានៅប្រទេសអ្នកមានមួយចំនួន មានកម្រិតទាបជាងការរំពឹងទុក ហើយប្រទេសខ្លះត្រូវប្រឹងប្រយុទ្ធនឹងបរិត្តផរណា។

អតិផរណានៅកម្ពុជានៅថេរ ត្រឹម ១,០% ធៀបឆ្នាំមុន។ សាំងចុះថ្លៃ នាំឲ្យអតិផរណាធ្លាក់ចុះ។ អតិផរណានៅឥណ្ឌូនេស៊ីឡើងដល់ ៧,១% ធៀបនឹង ៦,៦% កាលពីត្រីមាសមុន។ កម្រិតនិងភាពឆាប់ប្រែប្រួលនៃអតិផរណានៅឥណ្ឌូនេស៊ី វាខ្លាំងក្លាជាងនៅបណ្ដាប្រទេស មានសេដ្ឋកិច្ចកំពុងផុសឡើងស្រដៀងៗគ្នា។ សិង្ហបុរី បានជួបបរិត្តផរណាបីត្រីមាសជាប់ៗគ្នាកន្លងមក។ នៅត្រីមាសទី២ បរិត្តផរណានៅសិង្ហបុរី មានដល់ ០,៤% ដែលជាកម្រិតទាបបំផុតក្នុងពេល ៤ឆ្នាំកន្លងមក។ នៅត្រីមាសទី២ ថៃក៏មានបរិត្តផរណាដល់ ១,១% ដែរ រីឯនៅវៀតណាម អតិផរណាធ្លាក់ចុះមកត្រឹម ១,០% ធៀបនឹង ៤,៧% កាលពីឆ្នាំមុន។

អតិផរណានៅតែមានកម្រិតទាបនៅប្រទេសចិន និងនៅប្រទេសខ្លាអាស៊ីឯទៀត។ នៅចិន អតិផរណាកើនឡើងបន្តិច ដល់ ១,៤% ដោយសារការឡើងថ្លៃអាហារ។ អតិផរណារួមចុះមកត្រឹម ៣,១% នៅហុងកុង និង ០,៥% នៅកូរ៉េខាងត្បូង។ តៃវ៉ាន់ជួបនឹងបរិត្តផរណាដល់ ០,៧%។ អតិផរណាក្នុងតំបន់ចាយប្រាក់អឺរ៉ូឡើងដល់ ០,២% ឯនៅជប៉ុន វាធ្លាក់ចុះមកត្រឹម ០,៥% ហើយនៅសហរដ្ឋអាមេរិក វាកើនពី -០,៤% មកដល់សូន្យ។

នៅត្រីមាសទី២ ប្រាក់រៀល ធ្លាក់ថ្លៃ ០,៧% ធៀបនឹង ឆ្នាំមុន ទល់នឹងប្រាក់ដុល្លារ មកត្រឹម ៤០៥៦,៧រៀល/ដុល្លារ។ ប្រាក់បាតថៃ ធ្លាក់ថ្លៃ ២,៥% ធៀបនឹងឆ្នាំមុន ទល់នឹងប្រាក់ដុល្លារ ហើយប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ៣,៨%។ ប្រាក់យន់ចិន ឡើងថ្លៃ ០,៥% ទល់នឹងប្រាក់ ដុល្លារ ធៀបនឹងឆ្នាំមុន រីឯប្រាក់យេនជប៉ុន ធ្លាក់ថ្លៃ ១៨,៩%។

## ថ្លៃទំនិញនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី២ ទំនិញសំខាន់ៗក្នុងទីផ្សារពិភពលោក ធ្លាក់ថ្លៃ បើធៀបនឹងឆ្នាំមុន។ ពោត ធ្លាក់ថ្លៃ ២១,៦% មកត្រឹម ១៦៨,៤ដុល្លារ/តោន។ ប្រេងដូងប្រេង ធ្លាក់ថ្លៃ ២៥,២% មកត្រឹម ៦៦៤.០ដុល្លារ/តោន ហើយកៅស៊ូ ធ្លាក់ថ្លៃ ១៤,២% មកត្រឹម ១៥២៥,៩ដុល្លារ/តោន។ អង្ករ ធ្លាក់ថ្លៃ ៣,៧% ហើយសណ្ដែកសៀង ធ្លាក់ថ្លៃ ៣០,៤%។ ប្រេងឆៅ ធ្លាក់ថ្លៃ ៤២,៩% មកត្រឹម ៦០,៥ដុល្លារ/ធុង ដែលនាំឲ្យប្រេងសាំង និងប្រេងម៉ាស៊ូត ធ្លាក់ថ្លៃអស់ ៣៣,៩% និង ៣៧,២% រៀងគ្នា។

---

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រ៊ី បុប្ផារ័ត្ន ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.2 | 6.7 | 0.1 | 6.0 | 7.1 | 7.3 | 7.4 | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.3 | 6.1 | 4.2 | 6.2 | 6.5 | 6.3 | 5.8 | 5.2 | 5.1 | 5.0 | 5.4 | 4.7 |
| ម៉ាឡេស៊ី | 6.3 | 4.6 | -2.4 | 9.0 | 4.9 | 5.4 | 4.6 | 6.2 | 6.4 | 5.6 | 5.8 | 5.6 |
| សិង្ហបុរី | 7.7 | 1.1 | -4.5 | 14.7 | 4.7 | 1.3 | 3.8 | 5.1 | 2.4 | 2.4 | 2.1 | 2.6 |
| ថៃ | 4.9 | 2.6 | 3.3 | 7.9 | 0.0 | 6.7 | 2.8 | 3.1 | 0.3 | 0.6 | 2.2 | 3.3 |
| វៀតណាម | 8.5 | 6.2 | 4.7 | 6.4 | 6.2 | 5.2 | 5.4 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 11.9 | 9.0 | 8.2 | 10.4 | 9.3 | 7.7 | 7.7 | 7.1 | 7.5 | 7.3 | 7.3 | 7.1 |
| ហុងកុង | 6.4 | 2.4 | -3.2 | 6.9 | 4.9 | 2.9 | 3.0 | 2.5 | 1.8 | 2.7 | 2.2 | 2.1 |
| កូរ៉េខាងត្បូង | 4.9 | 2.2 | -1.0 | 6.1 | 3.6 | 2.1 | 2.8 | 4.1 | 3.5 | 3.2 | 2.8 | 2.4 |
| តៃវ៉ាន់ | 5.2 | 0.1 | -3.6 | 11.1 | 4.2 | 1.2 | 2.2 | 3.1 | 3.7 | 3.8 | 3.3 | 3.4 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.9 | 0.9 | -3.8 | 1.6 | 1.6 | -0.5 | 0.1 | 0.9 | 0.7 | 0.3 | 0.9 | 1.0 |
| ជប៉ុន | 2.0 | -0.7 | -5.4 | 4.1 | -0.8 | 1.7 | 1.7 | 3.1 | -0.1 | -1.2 | 0.5 | -0.9 |
| សហរដ្ឋអាមេរិក | 2.2 | 1.1 | -2.5 | 2.7 | 1.8 | 2.1 | 1.8 | 2.3 | 2.6 | 2.3 | 2.4 | 2.7 |

Sources: International Monetary Fund, Economist and countries' statistic offices

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (កំណើនថ្លៃជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 10.5 | 19.7 | -0.5 | 4.1 | 5.5 | 3.0 | 3.0 | 4.5 | 4.9 | 4.0 | 2.2 | 1.0 |
| ឥណ្ឌូណេស៊ី | 6.4 | 10.1 | 4.7 | 5.1 | 5.4 | 4.3 | 7.0 | 7.7 | 7.1 | 4.3 | 6.5 | 6.6 |
| ម៉ាឡេស៊ី | 2.0 | 5.3 | 0.4 | 1.7 | 3.2 | 1.7 | 2.1 | 3.5 | 3.3 | 3.0 | 2.8 | 0.7 |
| សិង្ហបុរី | 2.1 | 6.5 | 0.5 | 2.9 | 5.2 | 4.6 | 2.3 | 1.0 | 2.3 | 0.9 | -0.1 | -0.3 |
| ថៃ | 2.2 | 5.5 | -0.9 | 3.1 | 3.8 | 3.0 | 2.2 | 2.0 | 2.5 | 2.0 | 1.1 | -0.5 |
| វៀតណាម | 8.3 | 23.3 | 7.3 | 9.0 | 18.6 | 9.3 | 6.6 | 4.8 | 4.7 | 4.5 | 5.4 | 0.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 4.8 | 5.9 | -0.8 | 3.2 | 5.4 | 2.7 | 2.6 | 2.1 | 2.2 | 2.0 | 1.5 | 1.2 |
| ហុងកុង | 2.0 | 4.3 | -0.3 | 2.4 | 5.3 | 4.1 | 4.0 | 4.1 | 3.6 | 4.9 | 5.0 | 4.4 |
| កូរ៉េខាងត្បូង | 2.5 | 4.6 | 2.8 | 3.0 | 4.4 | 2.1 | 1.1 | 1.1 | 1.6 | 1.4 | 1.0 | 0.6 |
| តៃវ៉ាន់ | 1.8 | 3.2 | -1.1 | 1.0 | 1.4 | 1.9 | 0.8 | 1.1 | 1.6 | 1.5 | 1.6 | 2.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 3.3 | 0.4 | 1.6 | 2.7 | 2.5 | 1.4 | 0.6 | 0.6 | 0.4 | 0.2 | -0.3 |
| ជប៉ុន | 0.1 | 1.4 | -1.3 | -0.7 | 0.1 | -0.03 | 0.4 | 1.5 | 3.6 | 3.4 | 2.6 | 2.3 |
| សហរដ្ឋអាមេរិក | 2.9 | 3.8 | -0.4 | 1.7 | 3.2 | 2.1 | 1.5 | 1.4 | 2.1 | 1.8 | 1.3 | -0.4 |

Sources: International Monetary Fund, Economist and National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៧-២០១៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4062.7 | 4054.2 | 4140.5 | 4187.1 | 4063.6 | 4037.8 | 5369.6 | 3993.8 | 4026.9 | 4059.5 | 4070.1 | 4042.2 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9419 | 9699 | 10413.8 | 9089.9 | 4374.0 | 9363.0 | 13892.2 | 11765.8 | 11615.3 | 11775.7 | 12244.1 | 12809.9 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.3 | 3.5 | 3.2 | 1.5 | 3.1 | 4.2 | 3.3 | 3.2 | 3.2 | 3.4 | 3.6 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.51 | 1.42 | 1.5 | 1.4 | 1.3 | 1.2 | 1.7 | 1.3 | 1.3 | 1.3 | 1.3 | 1.4 |
| ថៃ (បាត) | 32.22 | 33.36 | 34.3 | 31.7 | 30.5 | 31.1 | 41.0 | 32.6 | 32.4 | 32.1 | 32.7 | 32.6 |
| វៀតណាម (ដុង) | 16030.0 | 16382 | 17725.2 | 19200.8 | 20574.3 | 20856.9 | 27987.1 | 21093.8 | 20923.2 | 21221.9 | 21314.0 | 21372.9 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 8.03 | 6.94 | 6.8 | 6.8 | 6.5 | 6.3 | 8.2 | 6.1 | 6.2 | 6.2 | 6.1 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 10.3 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 929.0 | 1137.2 | 1277.8 | 1156.3 | 1108.6 | 1126.6 | 1460.0 | 1069.7 | 1028.9 | 1027.5 | 1088.4 | 1101.7 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.9 | 31.5 | 33.0 | 31.3 | 29.4 | 29.6 | 39.6 | 30.3 | 30.1 | 30.0 | 30.9 | 31.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.7 | 0.8 | 0.7 | 0.8 | 0.7 | 0.8 | 1.0 | 0.7 | 0.7 | 0.8 | 0.8 | 0.9 |
| ជប៉ុន (យ៉េន) | 117.8 | 102.5 | 93.6 | 87.8 | 79.9 | 79.8 | 130.2 | 102.8 | 102.1 | 104.0 | 114.6 | 119.2 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៧-២០១៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - USA (USD/តោន) | 163.7 | 223.1 | 165.5 | 185.9 | 291.7 | 298.4 | 259.4 | 209.9 | 214.0 | 174.1 | 173.5 | 174.2 |
| ដូងប្រេង-អឺរ៉ុបពាយព្យ (USD/តោន) | 780.3 | 948.5 | 682.8 | 900.8 | 1125.4 | 999.3 | 856.9 | 911.3 | 887.1 | 772.0 | 715.3 | 627.9 |
| កៅស៊ូ SMR 5 (USD/តោន) | 0.0 | 1431.6 | 1884.8 | 3405.7 | 4630.6 | 3200.7 | 2575.3 | 2034.7 | 1777.6 | 1672.1 | 1538.1 | 1450.2 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 305.4 | 615.3 | 524.5 | 506.6 | 558.5 | 594.8 | 533.8 | 450.7 | 411.7 | 447.0 | 430.3 | 426.0 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 384.0 | 522.8 | 436.9 | 449.8 | 540.7 | 591.4 | 538.4 | 552.3 | 517.8 | 457.3 | 439.7 | 363.9 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 66.8 | 99.4 | 57.7 | 76.8 | 106.2 | 109.5 | 105.9 | 104.7 | 105.9 | 100.8 | 73.4 | 50.9 |
| សាំង - US Gulf Coast (សេន/លីត្រ) | 52.2 | 68.1 | 40.8 | 53.3 | 71.9 | 74.6 | 71.2 | 70.1 | 74.1 | 70.0 | 48.3 | 40.1 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 55.5 | 76.2 | 43.0 | 56.1 | 75.7 | 80.7 | 78.4 | 77.5 | 77.1 | 73.7 | 57.5 | 44.6 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី២ ឆ្នាំ២០១៥ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ រួមចុះ ៩១,១% ធៀបនឹងត្រីមាសមុន និង ៣៣,២% ធៀបមួយឆ្នាំមុន មកត្រឹម ២៥៤,៦លានដុល្លារ។ វិនិយោគក្នុងវិស័យកសិកម្ម កើន ៤៧,៤% ធៀបត្រីមាសមុន ដល់ ៣៨,១លានដុល្លារ និងមានចំណែក ១៥,០% នៃវិនិយោគសរុប។ វិនិយោគក្នុងវិស័យឧស្សាហកម្ម រួមចំណែក ៥១,៤% នៃវិនិយោគសរុប។ វិនិយោគក្នុងវិស័យកាត់ដេរ ធ្លាក់ចុះ ៣៣,៦% ធៀបត្រីមាសមុន មកត្រឹម ៤២,៤លានដុល្លារ។ វិនិយោគក្នុងវិស័យសេវាកម្ម រួមចំណែក ៣៣,៦% នៃវិនិយោគសរុប ប៉ុន្តែក្នុងត្រីមាសទី២នេះ គ្មានអនុមតិវិនិយោគក្នុងអនុវិស័យសណ្ឋាគារ និងទេសចរណ៍ទេ។

នៅត្រីមាសទី២ ឆ្នាំ២០១៥ ភ្ញៀវទេសចរបរទេសមកដល់កម្ពុជាសរុប ធ្លាក់ចុះ ២៧,៦% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើន ៦,៥% បើធៀបនឹងត្រីមាសដូចគ្នា កាលពីឆ្នាំមុន។ ភ្ញៀវមកដល់តាមផ្លូវអាកាស ធ្លាក់ចុះ ៣១,៤% ហើយតាមផ្លូវគោក និងផ្លូវទឹក ធ្លាក់ចុះ ២៣,៣% ធៀបនឹងត្រីមាសមុន។ ចំនួនភ្ញៀវមកពីប្រទេសប្រភពទេសចរចម្បងគេសម្រាប់កម្ពុជា ដូចជា វៀតណាម ចិន និង កូរ៉េខាងត្បូង បានថយចុះ។ ការកើតរាលដាលជំងឺ Middle East respiratory syndrome (MERS) អាចជាដើមហេតុមួយនៃការថយចុះនេះ។

ការនាំចេញសរុប កើន ០,៥៥% ធៀបនឹងត្រីមាសមុន និង ១៧,៣% ធៀបឆ្នាំមុន។ ការនាំចេញសម្លៀកបំពាក់ កើន ៣,៤២% ធៀបនឹងត្រីមាសមុន ពី ១៥៤៨,៨លានដុល្លារ ដល់ ១៦០១,៧លានដុល្លារ។ ការនាំចេញទៅសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក កើន ១១,១% និង ០,៧% រៀងគ្នា ធៀបនឹងត្រីមាសមុន ប៉ុន្តែការនាំចេញទៅប្រទេសសមាជិកអាស៊ាន ធ្លាក់ចុះ ០,៨% និងទៅប្រទេសជប៉ុន ធ្លាក់ចុះ ២២,៩% ។ ការនាំចេញផលិតផលកសិកម្មធ្លាក់ចុះ ១៩,១%ធៀបនឹងត្រីមាសមុន ក្នុងនោះ ការនាំចេញឈើធ្លាក់ចុះ ២៩,៤% កៅស៊ូធ្លាក់ចុះ ១,៨% អង្ករធ្លាក់ចុះ ១៩,១% ហើយផលិតផលកសិកម្មផ្សេងទៀតធ្លាក់ចុះ ២១,៧%។

នៅត្រីមាសទី២ ឆ្នាំ២០១៥ ការនាំចូល រួមចុះ ៧,៥% ធៀបនឹងត្រីមាសមុន និង ១៩,០% ធៀបឆ្នាំមុន មកត្រឹម ២៩២០,៣លានដុល្លារ។ ការនាំចូលសាំង កើន ៤,៨% ហើយការនាំចូលសម្ភារសំណង់ កើន ២២,៤% ប៉ុន្តែការនាំចូលម៉ាស៊ូត ធ្លាក់ចុះ ៧,៨%។

អត្ថបទនេះ រៀបរៀងដោយលោកស្រី ស្រ៊ី បុប្ផារ័ត្ន ជាអ្នកស្រាវជ្រាវ និង លោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី២ ឆ្នាំ២០១៥ ចំណូលរដ្ឋាភិបាលសរុប កើន ២៥,៤% ធៀបនឹងត្រីមាសមុន ដល់ ៣៣០១,៦ប៊ីលានរៀល ក្នុងនោះ ចំណូលចរន្ត កើន ២៤,៨% ដល់ ៣២៧៤,៥ប៊ីលានរៀល។ ចំណូលពន្ធ កើន ២៤,៤% ដល់ ៣០០៦,១ប៊ីលានរៀល ដោយរួមចំណែកបាន ៩១,០% ក្នុងចំណូលរដ្ឋាភិបាលសរុប។ ចំណូលមិនមែនពន្ធ កើន ២៩,៨% ដល់ ២៦៨,៥ប៊ីលានរៀល។ នៅត្រីមាសដដែល ចំណាយសរុប ធ្លាក់ចុះ ១៦,៥% ធៀបនឹងត្រីមាសមុន មកត្រឹម ១៧៣៧,២ប៊ីលានរៀល ដោយសារការធ្លាក់ចុះ ៤៣,១% នៃចំណាយមូលធន មកត្រឹម ៣៧១,៣ ប៊ីលានរៀល និង ការធ្លាក់ចុះ ៤,៤% នៃចំណាយចរន្ត មកត្រឹម ១៣៦៥,៩ប៊ីលានរៀល។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី២ ឆ្នាំ២០១៥ ថ្លៃទំនិញសរុប កើន ១,០% ធៀបនឹងឆ្នាំមុន។ ថ្លៃស្បៀងអាហារ និងភេសជ្ជៈមិនមែនស្រា កើន ៣,៩% រីឯថ្លៃដឹកជញ្ជូនធ្លាក់ចុះ ៧,៩%។ ប្រាក់រៀល ធ្លាក់ថ្លៃ ០,៤% ទល់នឹងប្រាក់ដុល្លារ ប៉ុន្តែឡើងថ្លៃ ១,៤% ទល់នឹងប្រាក់បាតថៃ និង ១,០% ទល់នឹងប្រាក់ដុងវៀតណាម ធៀបនឹងត្រីមាសមុន។ មាស ធ្លាក់ថ្លៃ ៤,៣% ធៀបត្រីមាសមុន ប៉ុន្តែម៉ាស៊ូត ឡើងថ្លៃ ៥,៥% ហើយសាំង ឡើងថ្លៃ ៥,១%។

## ស្ថានភាពក្រីក្រ

នៅខែសីហា ២០១៥ ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយ កម្មករកាត់ដេរ អ្នកជាក់ស៊ីក្លូ អ្នកស៊ីឈ្នួលធ្វើស្រែ អ្នករត់ម៉ូតូឌុប អ្នកបម្រើភោជនីយដ្ឋាន និង អ្នកលីសែង បាន កើនឡើង ធៀបនឹងខែសីហា ឆ្នាំមុន រីឯប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ ៣ក្រុមពលករងាយរងគ្រោះផ្សេងទៀត ធ្លាក់ចុះ។

គិតចាប់ពីខែមិថុនា ២០១៥ មក មានតែ ២ក្រុមពលករងាយរងគ្រោះប៉ុណ្ណោះ ដែលកើនប្រាក់ចំណូល។ អ្នកស៊ីឈ្នួលធ្វើស្រែ អាចរកការងារបានច្រើនជាងមុន ហើយកើនចំណូល ២២% ដល់ ៩៨៦៩រៀល/ថ្ងៃ។ អ្នកផ្តល់សម្ភាសន៍ ៧៥% ប្រាប់ថា ពួកគេជាប្រភពចំណូលចម្បងសម្រាប់គ្រួសារខ្លួន។ ពួកគេ ៤៥% ក៏រកចំណូលពីប្រភពផ្សេងទៀត ដូចជា ការបេះប្រមូលផលធានារួម និងការលក់ពលកម្មនៅកន្លែងផ្សេងទៀត។ ពួកគេ ៥៥% ទទួលកម្ចីពីសាច់ញាតិ ឬអ្នកចងការប្រាក់។

ចំណូលប្រចាំថ្ងៃរបស់កម្មករកាត់ដេរ កើន ៤,៨% ដល់ ១៥.៥១៥រៀល។ ជាមធ្យម ពួកគេរៀនបានត្រឹមថ្នាក់ទី៦ ហើយមានតែ ១៩% ប៉ុណ្ណោះ ដែលបានចូលរៀនវគ្គកាត់ដេរមុនពេលចាប់ផ្តើមការងារ រីឯអ្នកផ្សេងទៀត ទទួលបានការបណ្តុះបណ្តាលភ្ជាប់នឹងការងារតែម្តង។ ជាមធ្យម កម្មករកាត់ដេរ ធ្វើការ ៦ថ្ងៃ ឬ ៥៥ម៉ោង/សប្តាហ៍។ កម្មករកាត់ដេរចំណាយសរុបអស់ ៣៩% នៃចំណូលរបស់ខ្លួន ក្នុងនោះចំណាយលើអាហារមាន ៧០% និងថ្លៃជួលផ្ទះ ១៨%។ ពួកគេ ៧៣% មិនអាចសន្សំប្រាក់សម្រាប់ថ្ងៃអនាគតឡើយ។ អ្នកផ្តល់សម្ភាសន៍ ៤១រូប ប្រាប់ថា ប្រសិនបើរោងចក្រកាត់ដេរត្រូវបិទទ្វារ ពួកគេនឹងត្រឡប់ទៅផ្ទះវិញ។

នៅខែសីហា ២០១៥ ចំណូលរបស់អ្នកលក់បន្លែ ធ្លាក់ចុះ ២១% ធៀបនឹងអង្កេតលើកមុន មកត្រឹម ១៤.៤២៣រៀល/ថ្ងៃ ដែលជាការធ្លាក់ចុះខ្លាំងបំផុត បើធៀបនឹងក្រុមផ្សេងទៀត។ មានតែអ្នកលក់បន្លែ ១០% ប៉ុណ្ណោះ ដែលរស់នៅក្នុងរាជធានីភ្នំពេញ រីឯអ្នកដទៃទៀត ភាគច្រើនមកពីខេត្តកណ្តាល និងព្រៃវែង។ អ្នកលក់បន្លែ៧៣%មកលក់តែម្នាក់ឯង។ពួកគេជួលផ្ទះស្នាក់នៅរួមគ្នាដោយជាមធ្យមមានគ្នាបួននាក់។ ពួកគេចំណាយជាមធ្យម ៣០% នៃចំណូលសរុបរបស់ខ្លួន ហើយក្នុងនោះចំណាយលើស្បៀងអាហារ មានដល់ ៩៤%។ ពួកគេ មិនអាចសន្សំប្រាក់ដើម្បីពង្រីកអាជីវកម្មបានទេព្រោះចំណូលរកបានមិនទាំងគ្រប់សម្រាប់ទ្រទ្រង់ជីវភាពគ្រួសារផង។

ចំណូលរបស់អ្នករើសអេតចាយ ធ្លាក់ចុះ ១៤% មកត្រឹម ១២.២៣៧រៀល/ថ្ងៃ ដោយសារកំណើនចំនួនអ្នករើសអេតចាយនៅតំបន់ចាក់សម្រាម។ អ្នកផ្តល់សម្ភាសន៍ ៨៨% ប្រាប់ថា ពួកគេមករាជធានីភ្នំពេញជាមួយគ្រួសារហើយ៣២%ត្រូវត្រឡប់ទៅភូមិកំណើតវិញម្តងម្កាល ដើម្បីស៊ីឈ្នួលធ្វើស្រែចំការ នៅពេលពួកគេមិនអាចរកចំណូលបានច្រើននៅរាជធានីភ្នំពេញ។ ជាមធ្យម អ្នករើសអេតចាយ ចាយវាយអស់ ៣១% នៃចំណូលសរុបរបស់ខ្លួនជាពិសេសទៅលើអាហារ។ ចំណាយលើកន្លែងស្នាក់នៅ មានជាមធ្យម ៣៧.០០០រៀល/ខែ។

ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ ធ្លាក់ចុះ ៩,៩% មកត្រឹម ១៣.៩១៦រៀល ដោយសារការងារមានតិចជាងមុន ហើយកម្មករមានចំនួនច្រើនជាងមុន។ កម្មករផ្តល់សម្ភាសន៍ចេញមកពីខេត្តព្រៃវែង និងស្វាយរៀង។ ពួកគេជាប្រភពចំណូលចម្បងក្នុងគ្រួសារ ហើយប្រាក់ចំណូលរបស់ពួកគេអាចជួយទ្រទ្រង់គ្រួសារបានខ្លះៗ។ ពួកគេចាយវាយប្រចាំថ្ងៃអស់ ៣៧% នៃចំណូលសរុប ហើយភាគច្រើនទៅលើម្ហូបអាហារ។

ចំណូលរបស់អ្នកលីសែង ធ្លាក់ចុះ ៩,៣% ធៀបនឹងអង្កេតលើកមុន មកត្រឹម ១៤.៣១៤រៀល/ថ្ងៃ។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់ សុទ្ធតែមកពីខេត្ត ហើយភាគច្រើនមកពីខេត្តព្រៃវែង (៧០%)។ ពួកគេស្នាក់នៅរួមគ្នាជាមធ្យម ៦នាក់ ហើយបង់ថ្លៃជួលកន្លែងស្នាក់នៅអស់ ៦៥.០០០រៀល/ខែ។ ពួកគេចំណាយភាគច្រើនទៅលើម្ហូបអាហារ គឺរហូតដល់ ៣៧% នៃចំណូលសរុប ហើយមាន ៦០% ប្រាប់ថា បានសន្សំប្រាក់ខ្លះដើម្បីជួយទ្រទ្រង់ដល់គ្រួសារក្នុងការចិញ្ចឹមសត្វនៅផ្ទះ។

ចំណូលប្រចាំថ្ងៃរបស់អ្នកបម្រើភោជនីយដ្ឋាន ធ្លាក់ចុះ ៧,៣% មកត្រឹម ៨១០០រៀល។ អ្នកឆ្លើយតប ៩៣% ប្រាប់ថា ពួកគេស្នាក់នៅកន្លែងធ្វើការ។ ពួកគេចាយវាយប្រចាំថ្ងៃតែទៅលើម្ហូបអាហារប៉ុណ្ណោះ ដែលស្មើនឹង ២៩% នៃចំណូលសរុបរបស់ខ្លួន។ ពួកគេមិនអាចសន្សំប្រាក់ទុកបានឡើយ ព្រោះត្រូវផ្ញើប្រាក់នៅសល់ពីការចាយវាយ ទៅឲ្យគ្រួសារ។ ទោះយ៉ាងណាក្តី ប្រាក់នោះអាចជួយទ្រទ្រង់គ្រួសារបានតែមួយផ្នែកប៉ុណ្ណោះ។

# តាមដានសេដ្ឋកិច្ច - សូចនាករ

## តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៨-១៥*

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 92 | 615.0 | 530.7 | 725 | 531.6 | 930.5 | 28.9 | 27.6 | 0.0 | 0.0 | 25.8 | 38.08 |
| ឧស្សាហកម្ម | 724.9 | 818.5 | 403.7 | 2860.1 | 829.3 | 3257 | 179.0 | 239.3 | 434.3 | 149.9 | 342.8 | 130.91 |
| *កាត់ដេរ* | 142.8 | 90.1 | 122.8 | 393.9 | 497 | 324.1 | 109.3 | 172.4 | 81.6 | 30.3 | 63.9 | 42.4 |
| សេវាកម្ម | 10003.2 | 4432.0 | 1337.3 | 3425.4 | 916.6 | 140.7 | 219.1 | 114.4 | 191.5 | 0.0 | 2504.6 | 85.64 |
| *សណ្ឋាគារ និងទេសចរណ៍* | 8758.1 | 3980.1 | 1105.1 | 2850.9 | 691.5 | 106 | 163.3 | 15.4 | 268.1 | 0.0 | 60.6 | 0.0 |
| សរុប | 10570.9 | 5865.5 | 2271.7 | 7010.42 | 2278.0 | 4328 | 426.9 | 302.2 | 625.8 | 149.9 | 2873.2 | 254.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | -75.8 | -29.2 | 64.1 | -76.0 | 1816.8 | -91.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 308.6 | -44.5 | -61.3 | 209 | -67.5 | 90.1 | 95.1 | -81.8 | 142.7 | -91.5 | 573.0 | -33.2 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៨-១៥

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 376.2 | 213.9 | 220.1 | 405.1 | 547.3 | 658.9 | 133.6 | 84.0 | 33.1 | 20.4 | 122.3 |
| ផ្សេងៗ | 740.9 | 187.8 | 217.8 | 199.9 | 463.6 | 859.6 | 190.0 | 141.7 | 105.6 | 11.7 | 49.8 |
| សរុប | 1117.0 | 441.2 | 489.8 | 605.0 | 1010.9 | 1518.5 | 323.6 | 225.7 | 138.7 | 32.1 | 172.0 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | |
| សរុប | - | - | - | - | - | - | 34.3 | -30.2 | -38.5 | -77.8 | 437.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | |
| សរុប | 75.7 | -60.5 | 11.0 | 23.5 | 67.1 | 28.1 | 8.0 | -9.2 | -64.2 | -86.7 | -46.8 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៨-១៥

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 1239.4 | 1111.7 | 1304.3 | 1480.4 | 1722.1 | 2017.7 | 699.0 | 438.2 | 497.5 | 638.8 | 725.1 | 497.4 |
| តាមផ្លូវគោក និងទឹក | 881.9 | 999.7 | 1094.6 | 1401.4 | 1862.2 | 2192.5 | 569.0 | 495.2 | 501.2 | 663.9 | 647.6 | 496.7 |
| សរុប | 2121.3 | 2111.5 | 2398.9 | 2881.8 | 3584.3 | 4210.2 | 1268.0 | 933.4 | 998.7 | 1302.7 | 1372.6 | 994.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | | 10.0 | -26.4 | 7.0 | 30.4 | 5.4 | -27.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 5.0 | -0.5 | 13.6 | 20.1 | 24.4 | 17.5 | 8.0 | 1.4 | 3.5 | 13.0 | 8.3 | 6.5 |

Source: Ministry of Tourism

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៨-១៥*

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 3097.8 | 2901.6 | 3630.2 | 4929.5 | 6106.4 | 6982.4 | 1976.5 | 1859.8 | 2132.5 | 2137.1 | 2170.1 | 2182 |
| ក្នុងនេះ៖ សម្លៀកបំពាក់ទៅ | 2986.2 | 2565.3 | 3223.4 | 4259.6 | 5015.4 | 5386.1 | 1464.0 | 1379.2 | 1624.7 | 1492.6 | 1548.8 | 1601.7 |
| *- សហរដ្ឋអាមេរិក* | 1908.3 | 1512.6 | 1853.9 | 2055.3 | 2143.3 | 2075.2 | 531.1 | 452.5 | 511.2 | 468.8 | 491.08 | 494.3 |
| *- សហភាពអឺរ៉ុប* | 689.0 | 644.7 | 809.5 | 1322.2 | 1716.9 | 1969.6 | 532.7 | 558.5 | 673.8 | 638.7 | 617.3 | 685.9 |
| *- អាស៊ាន* | 10.8 | 6.9 | 9.9 | 17.6 | 39.4 | 60.2 | 21.9 | 19.3 | 20.5 | 21.7 | 24.8 | 24.6 |
| *- ជប៉ុន* | 25.2 | 44.5 | 86.5 | 147.0 | 188.6 | 278.7 | 101.4 | 74.9 | 117.6 | 89.2 | 121.4 | 93.6 |
| *- ប្រទេសផ្សេងៗ* | 352.9 | 356.5 | 463.6 | 717.5 | 927.2 | 1002.9 | 277.0 | 273.9 | 301.6 | 274.2 | 294.2 | 303.4 |
| កសិកម្ម | 44.5 | 73.1 | 164.9 | 362.1 | 376.7 | 554.5 | 167.0 | 157.3 | 133.7 | 166.4 | 150.3 | 127.3 |
| *- កៅស៊ូ* | 35.8 | 51.6 | 89.1 | 197.6 | 176.6 | 175.2 | 31.7 | 40.0 | 34.8 | 47.5 | 41.7 | 40.9 |
| *- ឈើ* | 3.4 | 3.5 | 34.1 | 48.8 | 36.8 | 73.6 | 55.9 | 48.4 | 19.6 | 8.2 | 13.9 | 9.8 |
| *- ត្រី* | 2.3 | 3.9 | 2.8 | 3.1 | 2.0 | 1.2 | 0.3 | 0.2 | 0.1 | 0.2 | 0.2 | 0.2 |
| *- អង្ករ* | 2.6 | 10.9 | 34.7 | 106.6 | 146.4 | 262.3 | 57.9 | 52.8 | 55.8 | 82.0 | 89.5 | 72.4 |
| *- ផលិតផលកសិកម្មផ្សេងៗ* | 0.5 | 3.0 | 4.1 | 6.0 | 14.9 | 42.4 | 21.2 | 16.0 | 23.5 | 28.5 | 5.2 | 4.0 |
| ផ្សេងៗ | 67.1 | 263.2 | 242.0 | 307.9 | 714.4 | 1088.2 | 345.5 | 323.3 | 373.0 | 478.2 | 471.0 | 452.9 |
| ការនាំចូលសរុប ក្នុងនេះ៖ | 4272.0 | 4331.5 | 5190.6 | 6375.9 | 8593.3 | 8639.4 | 2238.2 | 2454.4 | 2794.8 | 2807.9 | 2717.3 | 2920.3 |
| សាំង | 84.9 | 91.13 | 108.6 | 294.4 | 308.0 | 306.4 | 77.4 | 83.2 | 80.2 | 93.9 | 34.5 | 92.2 |
| ម៉ាស៊ូត | 119.5 | 180.67 | 203.8 | 447.0 | 559.5 | 569.1 | 148.5 | 142.5 | 163.4 | 147.9 | 45.1 | 152.7 |
| សម្ភារសំណង់ | 56.3 | 49.74 | 57.6 | 48.1 | 66.1 | 80.8 | 27.8 | 29.2 | 29.0 | 31.6 | 12.4 | 42.0 |
| ផ្សេងៗ | 4011.8 | 4010.0 | 4820.6 | 5586.4 | 7659.1 | 7682.6 | 1984.5 | 2199.5 | 2522.2 | 2534 | 835.2 | 2633 |
| ជញ្ជីងពាណិជ្ជកម្ម | -1174.7 | -1429.9 | -1560.5 | -1446.4 | -1341.6 | -1610.9 | -261.7 | -589.5 | -662.3 | -670.8 | -547.2 | -738.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | 9.8 | -5.8 | 17.8 | -8.1 | 3.8 | 3.4 |
| ការនាំចេញសរុប | - | - | - | - | - | - | 8.9 | -5.9 | 14.7 | 0.2 | 1.5 | 0.5 |
| ការនាំចូលសរុប | - | - | - | - | - | - | 5.1 | 9.4 | 14.1 | 0.5 | -3.2 | 7.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 1.6 | -14.1 | 25.7 | 32.1 | 17.7 | 7.4 | 19.5 | 9.6 | 3.6 | 11.9 | 5.8 | 16.1 |
| ការនាំចេញសរុប | 1.6 | -6.3 | 25.1 | 35.8 | 23.9 | 14.3 | 25.3 | 14.8 | 8.3 | 17.7 | 9.8 | 17.3 |
| ការនាំចូលសរុប | 13.3 | 1.4 | 19.8 | 22.8 | 16.8 | 0.5 | 2.1 | 10.8 | 35.7 | 31.8 | 21.4 | 19.2 |

* Import data include tax-exempt imports.
Sources: Department of Trade Preference Systems, Ministry of Commerce and Customs and Excise Department, MEF (website)

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៨-១៥ (ប៊ីលានរៀល)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 5290.0 | 4885.2 | 5989.0 | 6251.4 | 7691.9 | 8255.2 | 2220.5 | 2793.7 | 2580.6 | 2948.6 | 2633.5 | 3301.6 |
| ចំណូលចរន្ត | 5210.7 | 4855.9 | 5859.1 | 6179.3 | 7443.8 | 8233.2 | 2219.2 | 2765.2 | 2571.4 | 2803.6 | 2623.7 | 3274.5 |
| ចំណូលពន្ធ | 4409.9 | 4268.0 | 4693.0 | 5277.5 | 6334.8 | 7198.1 | 1988.7 | 2383.1 | 2264.6 | 2358.8 | 2416.8 | 3006.1 |
| ពន្ធក្នុងស្រុក | 3248.4 | 3088.6 | 3533.6 | 4071.6 | 5002.8 | 5728.1 | 1593.6 | 1943.2 | 1798.0 | 1891.6 | 2002.8 | 2474.6 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 1161.5 | 1064.7 | 1159.4 | 1205.9 | 1331.7 | 1470.0 | 449.0 | 439.9 | 466.5 | 467.2 | 414.0 | 524.5 |
| ចំណូលមិនមែនពន្ធ | 800.8 | 702.1 | 1166.1 | 901.8 | 1118.2 | 1035.2 | 176.6 | 382.1 | 306.9 | 444.8 | 206.9 | 268.5 |
| ចំណូលលើទ្រព្យសម្បត្តិ | 78.0 | 64.6 | 291.1 | 63.8 | 143.0 | 84.0 | 11.1 | 40.8 | 21.2 | 15.4 | 3.0 | 16.7 |
| លក់ទំនិញ និងសេវា | 424.7 | 408.0 | 460.1 | 588.7 | 667.4 | 750.3 | 160.3 | 197.5 | 212.9 | 300.5 | 189.2 | 219.2 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | 298.2 | 228.2 | 408.9 | 249.3 | 298.8 | 200.8 | 5.2 | 143.7 | 72.7 | 128.9 | 14.7 | 32.6 |
| ចំណូលជាមូលធន | 79.3 | 29.3 | 129.9 | 72.1 | 247.9 | 73.4 | 1.3 | 28.5 | 9.2 | 145.0 | 9.8 | 27.1 |
| ចំណាយសរុប | 6297.8 | 7383.5 | 8784.6 | 9032.4 | 9660.9 | 12535.7 | 2618.8 | 2867.2 | 3349.0 | 4471.4 | 1958.1 | 1737.2 |
| ចំណាយជាមូលធន | 2574.4 | 2694.9 | 2853.2 | 3546.9 | 3628.3 | 5567.5 | 1187.1 | 1395.9 | 1421.7 | 1586.0 | 529.4 | 371.3 |
| ចំណាយចរន្ត | 3809.0 | 4440.0 | 4773.1 | 5341.2 | 6188.4 | 6968.3 | 1431.7 | 1471.4 | 1927.3 | 2885.4 | 1428.7 | 1365.9 |
| បៀវត្សរ៍ | 1397.0 | 2012.0 | 2048.8 | 2170.6 | 2486.6 | 2997.3 | 860.0 | 931.0 | 918.4 | 1046.1 | 935.1 | 945.8 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | 927.1 | 871.4 | 1099.4 | 1518.8 | 1586.8 | 1563.0 | 213.1 | 259.6 | 434.8 | 719.5 | 194.3 | 207.2 |
| ចំណាយចរន្តផ្សេងទៀត | 1384.9 | 1556.6 | 1624.8 | 1651.8 | 2115.1 | 2408.0 | 358.6 | 280.8 | 574.1 | 1119.9 | 299.3 | 201.1 |
| សមតុល្យជាទូទៅ | -1007.8 | -2498.3 | -2795.7 | -1271.4 | -1969.0 | -4280.6 | -398.4 | -73.5 | -768.5 | -522.8 | 675.5 | 1564.4 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 2055.1 | 1746.1 | 1845.2 | -2781.0 | 2457.8 | 4326.2 | 977.9 | 1123.9 | 1012.5 | 857.9 | 232.2 | 116.7 |
| ហិរញ្ញប្បទានក្នុងស្រុក | -127 | 474.9 | 938.6 | 2379.2 | -332.9 | 824.4 | -915.0 | -172.9 | -279.3 | -61.4 | -687.8 | -1159.4 |

Source: Ministry of Economy and Finance website

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៨-១៥

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 19.7 | -0.7 | 4.1 | 5.4 | 2.3 | 3.9 | 4.6 | 4.8 | 4.0 | 2.1 | 1.0 | 1.0 |
| - អាហារ និងភេសជ្ជៈមិនមែនស្រា | 33.1 | -0.3 | 4.4 | 6.5 | 2.5 | 4.9 | 5.7 | 5.3 | 5.1 | 3.4 | 4.2 | 3.9 |
| - ដឹកជញ្ជូន | 19.4 | -10.7 | 7.0 | 6.9 | 3.3 | -1.0 | -1.1 | 0.5 | -0.2 | -3.3 | -10.9 | -7.9 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4058.2 | 4140.5 | 4187.1 | 4063.6 | 4039.2 | 4036.2 | 3993.8 | 4026.9 | 4059.5 | 4064.7 | 4042.2 | 4056.7 |
| រៀលក្នុង ១ បាតថៃ | 123.5 | 121.1 | 133.1 | 133.2 | 130.0 | 124.9 | 123.0 | 124.8 | 127.1 | 124.6 | 124.4 | 122.6 |
| រៀលក្នុង ១០០ ដុងវៀតណាម | 24.8 | 23.4 | 21.7 | 19.7 | 19.4 | 19.1 | 19.1 | 19.2 | 19.2 | 19.1 | 19.0 | 18.8 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 105.9 | 113.1 | 147.5 | 184.5 | 200.9 | 152.3 | 156.6 | 155.9 | 155.5 | 141.1 | 150.9 | 144.4 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 4555.2 | 3170.9 | 3859.3 | 4761.2 | 4941.2 | 4852.1 | 4971.2 | 5006.7 | 5047.6 | 4382.8 | 3823.4 | 4032.0 |
| ថ្លៃសាំង (រៀល/លីត្រ) | 4750.8 | 3593.1 | 4368.1 | 5044.5 | 5312.7 | 5083.3 | 5171.5 | 5200.0 | 5348.6 | 4613.0 | 3986.2 | 4189.0 |

Sources: National Institute of Statistics, National Bank of Cambodia and CDRI

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៨-១៥ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | | | | 2015 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ប៊ីលានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 10345.0 | 14655.0 | 16697.9 | 17893.9 | 18154.5 | 21260.1 | 23344.4 | 26235.8 | 26817.8 | 26699.7 | 26823 | 27975.3 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | 1513.3 | 1573.0 | 2778.9 | 5760.8 | 10437.4 | 11508.3 | 11817.4 | 12024.4 | 13950.5 | 15859.8 | 16863.2 | 18178.3 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -2987.0 | -2252.0 | -2126.6 | -2123.1 | -2486.4 | -2794.9 | -3349.3 | -3747.3 | -4113.0 | -4359.1 | -5064 | -5666.1 |
| ឥណទានដល់ផ្នែកឯកជន | 9894.0 | 10532.0 | 13331.2 | 17552.8 | 23536.6 | 27608.8 | 28584.5 | 30621.3 | 33226.4 | 36244.6 | 37759.4 | 40995 |
| រូបិយវត្ថុទូទៅ M2 | 11858.0 | 16228.0 | 19476.8 | 23654.7 | 28591.9 | 32768.4 | 35161.8 | 38259.9 | 40768.3 | 42559.5 | 43685.2 | 46153.7 |
| រូបិយវត្ថុ M1 | 2399.0 | 3120.0 | 3220.9 | 3956.2 | 4045.7 | 4878.2 | 5376.2 | 5231.3 | 5583.1 | 6308.4 | 6628.0 | 6293.1 |
| រូបិយវត្ថុផ្សេងៗ | 9459.0 | 13108.0 | 16255.9 | 19698.5 | 24546.2 | 27890.2 | 29785.7 | 33028.5 | 35185.2 | 36251.1 | 37058.2 | 39860.6 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 4.8 | 36.9 | 20.0 | 17.8 | 20.9 | 14.6 | 15.4 | 20.8 | 38.9 | 29.9 | 24.2 | 20.6 |
| រូបិយវត្ថុ M1 | 16.9 | 30.1 | 3.2 | 16.9 | 2.3 | 20.6 | 19.5 | 14.1 | 18.3 | 29.3 | 23.3 | 20.3 |
| រូបិយវត្ថុផ្សេងៗ | 2.2 | 38.6 | 24.0 | 17.9 | 44.6 | 13.6 | 14.6 | 22.0 | 42.8 | 30.0 | 24.4 | 20.7 |

Source: National Bank of Cambodia

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2012 | 2013 | 2014 | | | | 2015 | | | 2015 | | |
| | | | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 10303 | 10,438 | 10,832 | 10764 | 9867 | 11634 | 12950 | 12467 | 11799 | 19.6 | 15.8 | 19.6 |
| អ្នកលីសែង | 12143 | 13247 | 12141 | 12590 | 13399 | 16189 | 16798 | 15782 | 14314 | 38.4 | 25.4 | 6.8 |
| អ្នកលក់បន្លែតូចតាច | 10771 | 11366 | 12294 | 13581 | 15373 | 17735 | 15007 | 18171 | 14423 | 22.1 | 33.6 | -6.2 |
| អ្នករើសអេតចាយ | 8680 | 9819 | 9593 | 9214 | 8337 | 9548 | 10627 | 14169 | 12237 | 10.8 | 53.8 | 46.8 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 6111 | 6697 | 7449 | 6696 | 7565 | 9435 | 8466 | 8742 | 8100 | 13.7 | 30.3 | 7.1 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 6151 | 6599 | 8932 | 5836 | 8494 | 6781 | 8,303 | 8063 | 9869 | -7.0 | 37.9 | 16.2 |
| កម្មកររោងចក្រកាត់ដេរ | 8932 | 10161 | 9548 | 11412 | 11607 | 12092 | 14644 | 14803 | 15515 | 53.4 | 29.7 | 33.7 |
| អ្នករត់ម៉ូតូឌុប | 12930 | 13450 | 13227 | 13401 | 12656 | 14259 | 14549 | 14692 | 14124 | 10 | 9.6 | 11.6 |
| កម្មករសំណង់គ្មានជំនាញ | 11078 | 13184 | 15162 | 15343 | 15401 | 15437 | 16678 | 15453 | 13916 | 10 | 0.7 | -9.6 |
| កម្មករសំណង់មានជំនាញ | 13743 | 15442 | 15163 | 15792 | 20420 | 18303 | 17050 | 19918 | 18905 | 12.4 | 26.1 | -7.4 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the incomes of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI

*តពីទំព័រ ២០* **ព័ត៌មានថ្មីៗ**...

ជាន់ខ្ពស់ស្ដីទីផ្នែករដ្ឋបាល (ជំនួសលោកនាយកផ្នែកប្រតិបត្តិការ) ហើយលោកស្រីមានបទពិសោធន៍ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងជាអ្នកគ្រប់គ្រងជាន់ខ្ពស់ស្ត្រីដំបូងគេនៅ CDRI។ ក្នុងកិច្ចប្រជុំនោះ មានការពិភាក្សាពីបែបបទអនុវត្តឲ្យបានសមស្របនូវអង្គការលេខថ្មីរបស់ CDRI ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងប្រតិបត្តិការ។

**៤ កញ្ញា**៖ លោកនាយកប្រតិបត្តិ បានធ្វើជាអ្នកសម្របសម្រួលវគ្គស្ដីពី "កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ពហុភាគីនៅតំបន់អាស៊ីប៉ូព៌ា" នៅក្នុងវេទិកាបណ្ដាវិទ្យាស្ថាននៅអាស៊ីប៉ូព៌ាលើកទី១១ ស្ដីពី "សហគមន៍សេដ្ឋកិច្ចអាស៊ាន និងហួសពីនោះទៀត៖ ទិដ្ឋភាពខាងក្នុង និងខាងក្រៅ" ដែលរៀបចំឡើងដោយ វិទ្យាស្ថានគោលនយោបាយសេដ្ឋកិច្ចអន្តរជាតិ (KIEP) និង វិទ្យាស្ថានសម្រាប់ការសិក្សាជាយុទ្ធសាស្ត្រនិងអន្តរជាតិ (ISIS) នៅក្នុងខេត្ត Kota Kinabalu ប្រទេសម៉ាឡេស៊ី។ លោកនាយកប្រតិបត្តិបានទៅចូលរួមក្នុងវេទិកានេះ ក្នុងកិច្ចប្រឹងប្រែងរបស់ CDRI ដើម្បីចែករំលែកបទពិសោធន៍របស់ខ្លួន ជាមួយក្រុមផ្ដល់គំនិតចម្បងៗឯទៀតនៅក្នុងតំបន់។

**៨-៩ កញ្ញា**៖ លោកនាយកប្រតិបត្តិ បានធ្វើបទបង្ហាញមួយស្ដីពី "ការកសាងសមត្ថភាពក្រុមផ្ដល់គំនិត ដើម្បីបង្កើនឥទ្ធិពលផ្នែកគោលនយោបាយ៖ បទពិសោធន៍ការងារ ២៥ឆ្នាំ របស់ CDRI" នៅក្នុងវេទិកាការអភិវឌ្ឍក្រុមផ្ដល់គំនិតនៅអាស៊ីឆ្នាំ២០១៥ ដែលរៀបចំឡើងដោយ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។ វេទិកាប្រចាំឆ្នាំនេះ សំខាន់បំផុតសម្រាប់ឲ្យ CDRI ចែករំលែកបទពិសោធន៍របស់ខ្លួនក្នុងការស្រាវជ្រាវផ្នែកគោលនយោបាយ ជាមួយក្រុមផ្ដល់គំនិតផ្សេងៗទៀតនៅក្នុងតំបន់។

**១៥-១៦ កញ្ញា**៖ CDRI បានរៀបចំសន្និសីទ DRF លើកទី៨ ស្ដីពី "ការកសាងសមត្ថភាពស្រាវជ្រាវសម្រាប់ សាកលវិទ្យាល័យ និងក្រុមផ្ដល់គំនិតនានានៅកម្ពុជា៖ តើត្រូវធ្វើអ្វីខ្លះ?" នៅសណ្ឋាគារកាំបូឌីយ៉ាណា នៅរាជធានីភ្នំពេញ។ សន្និសីទនេះព្យាយាមកសាងនូវសហគមន៍ស្រាវជ្រាវមួយ កំណត់អាទិភាព និងទិសដៅនៃការស្រាវជ្រាវ និងកំណត់ពីតម្រូវការ និងបញ្ហាប្រឈមក្នុងការជួយទ្រទ្រង់ដល់ការបង្កើត DRF ដំណាក់កាលទី៣។

## ការស្រាវជ្រាវ

### វិស័យកសិកម្ម

ក្រុមស្រាវជ្រាវបានបង្ហើយ ៣គម្រោង និងកំពុងអនុវត្ត ៧គម្រោង បន្តទៀត។ លទ្ធផលស្រាវជ្រាវ រួមមាន ឯកសារពិភាក្សាចំនួន ៤ ក្នុងនោះមាន ២ ជាការសិក្សារួមគ្នាជាមួយ អង្គភាពផ្នែកសុខភាពនៅក្នុង គម្រោងការស្រាវជ្រាវដើម្បីកសាងប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញបន្ទាប់ពីបានបញ្ចប់ទំនាស់ (ReBUILD)។ ឯកសារ ២ ទៀតគឺ "ផលប៉ះពាល់នៃការធ្វើកសិកម្មតាមកិច្ចសន្យា ទៅលើជីវភាពកសិករម្ចាស់ដីតូចៗ" និង "យន្តកម្មកសិកម្ម និងនិន្នាការទីផ្សារពលកម្មកសិកម្ម" បានទទួលការគាំទ្រពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida)។ ឯកសារទី៥ មានចំណងជើងថា "ផលប៉ះពាល់នៃគោលនយោបាយជំរុញការនាំចេញអង្ករ និងសន្តិសុខស្បៀង" ដែលជិតចេញផ្សាយហើយ។

ជិតចងក្រងបានរួចរាល់ដែរគឺរបាយការណ៍ព្រាងទី១សម្រាប់ការសិក្សាពី ផលិតកម្មសត្វចិញ្ចឹម និងការវិភាគខ្សែចង្វាក់បង្កើតតម្លៃដែលគាំទ្រដោយមជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR)។ ក្រុមស្រាវជ្រាវក៏កំពុងរៀបចំរបាយការណ៍ជឿនលឿនការងារសម្រាប់គម្រោងស្ដីពី ផលប៉ះពាល់នៃចំណាយសារធារណៈផ្នែកអប់រំ ទៅលើមូលធនមនុស្ស ភាពក្រីក្រ និង វិសមភាព៖ វិធីសាស្ត្រតុល្យភាពទូទៅ អាចគណនាបាន (Computable General Equilibrium: CGE) សម្រាប់កម្ពុជា ដែលអនុវត្តឡើងដោយមានជំនួយហិរញ្ញវត្ថុពីអង្គការ ភាពជាដៃគូសម្រាប់គោលនយោបាយសេដ្ឋកិច្ច (PEP)។ ការប្រមូលទិន្នន័យដល់កន្លែង និងការចាត់ចែងទិន្នន័យ បានអនុវត្តចប់សព្វគ្រប់ សម្រាប់ការសិក្សាផ្ដល់មូលនិធិដោយ FAO ស្ដីពី សកម្មភាពបង្កើតប្រាក់ចំណូលមិនមែនកសិកម្មនៅកម្ពុជា។

ឯកសារពិភាក្សាសម្រាប់គម្រោង ២ថ្មីទៀត កំពុងចងក្រងបញ្ចប់។ ឯកសារទី១ ផ្ដោតលើ ការវិភាគគោលនយោបាយស្រូវ៖ ផលពាក់ព័ន្ធនៃ គោលនយោបាយនាំចេញអង្កររបស់វៀតណាមសម្រាប់កម្ពុជា ដែលទទួលជំនួយហិរញ្ញវត្ថុពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈគំនិតផ្ដួចផ្ដើមផ្នែកគោលនយោបាយសារធារណៈ សម្រាប់ទន្លេមេគង្គក្រោម (LMPPI)។ ឯកសារទី២ ជារបាយការណ៍នៃការស្រាវជ្រាវរយៈពេលបីឆ្នាំ (២០១៥-១៨) លើ ការសាកល្បងគំរូបែបថ្មីនៃការផ្សព្វផ្សាយបច្ចេកទេសកសិកម្មនៅក្នុង គម្រោងអភិវឌ្ឍន៍កសិកម្ម និងជំរុញកំណើនសេដ្ឋកិច្ច (PADEE) របស់កម្ពុជា ដែលផ្ដល់មូលនិធិដោយ វិទ្យាស្ថានស្រាវជ្រាវពីគោលនយោបាយស្បៀងអាហារអន្តរជាតិ (IFPRI) និងគ្រោងចាប់ផ្ដើមនៅខែវិច្ឆិកា នេះ។ ដោយមានជំនួយហិរញ្ញវត្ថុពីមហាវិទ្យាល័យជាតិអូស្ត្រាលី (ANU) គម្រោងស្រាវជ្រាវរយៈពេល ៧ខែ ស្ដីពី កសិកម្មមានប្រព័ន្ធស្រោចស្រពនៅកម្ពុជា ត្រៀមចាប់ដំណើរការ នៅចុងខែតុលា ២០១៥។

### ផ្នែកសេដ្ឋកិច្ច

បន្ទាប់ពីបានផ្សព្វផ្សាយ សេចក្ដីប្រកាសឲ្យដាក់សំណើធ្វើការស្រាវជ្រាវជាលក្ខណៈប្រកួតប្រជែងក្នុងតំបន់ នៅក្រោមកម្មវិធីរយៈពេល ៣ឆ្នាំ នៃបណ្ដាញមហាអនុតំបន់មេគង្គ (GMS-Net) ស្ដីពី ការលើកស្ទួយអនាគតការងារសម្រាប់យុវជន៖ ទីផ្សារពលកម្ម ការអភិវឌ្ឍជំនាញ និងវិស័យឯកជន ក្នុងមហាអនុតំបន់មេគង្គ ដែលទទួលបានមូលនិធិពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដានោះ វិទ្យាស្ថាន CDRI បានជ្រើសរើសសំណើស្រាវជ្រាវល្អៗជាងគេ ចំនួន ៨ (មកពីកម្ពុជា ៣, មកពីវៀតណាម ២ និង មកពី ថៃ ឡាវ និង ចិន មាន ១ ក្នុងមួយប្រទេស) ដើម្បីផ្ដល់មូលនិធិឲ្យ។ អ្នកស្រាវជ្រាវនៃវិទ្យាស្ថាន CDRI បានទទួលមូលនិធិស្រាវជ្រាវមួយ សម្រាប់ធ្វើការសិក្សាពី ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការវិវត្តក្នុងទីផ្សារពលកម្ម៖

ការពិសោធដោយចៃដន្យ ក្នុងចំណោមជនកម្ពុជាទើបពេញវ័យ។ អ្នកសម្របសម្រួលគម្រោង GMS-Net កំពុងរៀបចំសិក្ខាសាលាផ្នែកបច្ចេកទេសលើកដំបូងមួយ សម្រាប់ក្រុមស្រាវជ្រាវទាំងអស់ ដោយគ្រោងធ្វើឡើងនៅពាក់កណ្ដាលខែវិច្ឆិកា ២០១៥។

ការចងក្រងរបាយការណ៍សម្រាប់គម្រោង ទំនាក់ទំនងរវាងគោលនយោបាយសាធារណៈរបស់ប្រទេសជាដៃគូ ចំណាកស្រុក និងការអភិវឌ្ឍ៖ ករណីសិក្សា និងអនុសាសន៍គោលនយោបាយ ដែលទទួលមូលនិធិពី អង្គការដើម្បីសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) កំពុងដំណើរការទៅមុខ។ សមាសភាគពីរចុងក្រោយ (គោលនយោបាយទីផ្សារពលកម្ម និងទីផ្សារឥណទាន) នៃគម្រោងស្រាវជ្រាវរយៈពេល ៥ឆ្នាំ ស្ដីពី កំណើនសម្រាប់គ្រប់គ្នា ដែលទទួលបានជំនួយទ្រទ្រង់ពី Sida មានការវិវត្តល្អទៅមុខ។ គម្រោងស្ដីពី ការពិនិត្យឡើងវិញលើការងារមិនទាន់ចប់៖ កត្តាកំណត់នានានៃ លទ្ធភាពទទួលបានឥណទាន និងផលប៉ះពាល់លើផលិតកម្មកសិកម្ម និងការប្រើប្រាស់ដីនៅតំបន់ជនបទកម្ពុជា ក៏កំពុងដំណើរការទៅមុខ ហើយក្រុមស្រាវជ្រាវបានជឿនលឿនច្រើន ក្នុងការសិក្សាលើឯកសារមានស្រាប់ និងការចងក្រងរបាយការណ៍បណ្ដោះអាសន្ន។

## ផ្នែកអប់រំ

របាយការណ៍សម្រេចសម្រាប់ អង្កេតគោលលើការវាយតម្លៃតម្រូវការបណ្ដុះបណ្ដាល ក្នុងបណ្ដាខេត្តនៅភាគខាងជើងប្រទេសកម្ពុជា ដែលជាគម្រោងរួមសហការអនុវត្តជាមួយអង្គភាពផ្នែកសេដ្ឋកិច្ច បានចប់សព្វគ្រប់។ នៅចុងខែកក្កដា ក្រុមស្រាវជ្រាវផ្នែកអប់រំ បានធ្វើបទបង្ហាញពីលទ្ធផលរកឃើញជូនដល់ ក្រុមអនុវត្តកម្មវិធីអភិវឌ្ឍន៍ជំនាញនៃទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការ (Skills Development Programme consortium of the Swiss Agency for Development and Cooperation) ហើយនៅក្នុងខែសីហា បានធ្វើបទបង្ហាញនេះជូនដល់ សមាជិកនៃក្រុមការងារសម្របសម្រួលសម្រាប់ការអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) នៅ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

សិក្ខាសិលាបណ្ដុះបណ្ដាលការស្រាវជ្រាវចំនួន ២ ស្ដីពី ការគ្រប់គ្រងឯកសារយោងដោយប្រើកម្មវិធីកុំព្យូទ័រ Zotero និងស្ដីពីការវិភាគទិន្នន័យបែបគុណភាពដោយប្រើកម្មវិធី NVivo ត្រូវបានធ្វើឡើងក្នុងខែសីហា ដោយមានក្រុមអ្នកស្រាវជ្រាវវ័យក្មេងមកចូលរួម រួមទាំង អ្នកស្ម័គ្រចិត្ត និងអ្នកហាត់ការផងដែរ។

នៅដើមខែកញ្ញា ប្រធានផ្នែកអប់រំបានដឹកនាំគណៈប្រតិភូមួយក្រុមរួមមានតំណាងមកពី ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងទេសចរណ៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ និងសមាគមសហគ្រិនស្ត្រីនៅកម្ពុជា ទៅធ្វើទស្សនកិច្ចនៅប្រទេសស្វីស ដើម្បីរៀនសូត្រដោយផ្ទាល់ពីប្រព័ន្ធអប់រំនិងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនៅស្វីស។ ប្រព័ន្ធអប់រំរបស់ស្វីស ត្រូវបានរចនារៀបចំតាមរបៀបមួយដែលផ្ដល់នូវ ផ្លូវយ៉ាងច្បាស់លាស់សម្រាប់ការចូលទៅបម្រើការងារនាពេលអនាគត ពោលគឺ អនុញ្ញាតឲ្យនិស្សិតអាចសិក្សាស្រាវជ្រាវពីជម្រើសការអប់រំ និងអាជីព ព្រមទាំងបំពាក់ឲ្យពួកគេនូវ ជំនាញសម្រាប់បម្រើការងារ តាមរយៈ វគ្គហាត់ការ និងការអនុវត្តការងារជាក់ស្ដែងបង្កើនបទពិសោធន៍។

## ផ្នែកបរិស្ថាន

គម្រោងរយៈពេលបីឆ្នាំផ្ដល់ជំនួយមូលនិធិដោយ IDRC ស្ដីពី ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចធនធានទឹកនៅកម្ពុជា ជិតចប់សព្វគ្រប់។ សិក្ខាសាលាថ្នាក់ខេត្ត និងថ្នាក់ជាតិដើម្បីបញ្ជាក់សុពលភាពគម្រោង ត្រូវបានរៀបចំឡើងនៅក្រុងព្រះសីហនុ និងក្រុងសៀមរាប ដើម្បីប្រមូលមតិយោបល់ទាក់ទងនឹងលទ្ធផលនៃ ការសិក្សាតូចៗមួយស៊េរីដែលបានអនុវត្តនៅក្នុងអនុដៃនរងទឹកភ្លៀងបីនៃអាងទន្លេសាបកម្ពុជា។ ការសិក្សាទាំងនោះ និងរបាយការណ៍សំយោគមួយ កំពុងចងក្រងជាសៀវភៅថ្មីមួយក្រោមចំណងជើងថា "បញ្ហាប្រឈម និងការប្រមើលពីសន្តិសុខទឹក និងការប្រែប្រួលអាកាសធាតុ ក្នុងអាងស្ទឹងមួយចំនួននៅកម្ពុជា" ដែលគ្រោងបោះពុម្ពផ្សាយនៅខែធ្នូ ២០១៥។

ការវិភាគទិន្នន័យ និងសរសេររបាយការណ៍ កំពុងដំណើរទៅមុខសម្រាប់ពីរគម្រោង។ គម្រោងទី១ សិក្សាស្វែងរកវិធីកែលំអការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ ដើម្បីថែរក្សា ឬបង្កើនការចូលរួមចំណែកនៅក្នុង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងសន្តិសុខស្បៀង។ គម្រោងនេះ ទទួលជំនួយទ្រទ្រង់ពី Sida ។ គម្រោងទី២ ស្ដីពី ការជំរុញជីវភាពរស់នៅឲ្យធន់នឹងការប្រែប្រួលអាកាសធាតុ សម្រាប់កសិករតូចតាចនៅតំបន់ដីស្ងួតងាយរងគ្រោះបំផុត ក្នុងខេត្តកំពង់ចាម និងក្រុងសៀមរាប ត្រូវបានអនុវត្តឡើងក្រោមកិច្ចសន្យាជាមួយអង្គការ Plan International Cambodia ។

ប្រធានក្រុមស្រាវជ្រាវផ្នែកបរិស្ថាន បានចូលរួមក្នុងព្រឹត្តិការណ៍ចំនួនបី ដើម្បីធ្វើបទបង្ហាញពី ១) "អភិបាលកិច្ចទឹក និងការប្រែប្រួលអាកាសធាតុនៅកម្ពុជា" នៅក្នុងវេទិកាស្រាវជ្រាវអភិវឌ្ឍន៍ប្រារព្ធឡើងនៅរាជធានីភ្នំពេញ ២) "គ្រោះមហន្តរាយ និងជីវភាពនៅកម្ពុជា"នៅក្នុងសិក្ខាសាលានៅទីក្រុងម៉ានីលប្រទេសហ្វីលីពីនលើការកាត់បន្ថយភាពក្រីក្រក្រោយមានខ្យល់ព្យុះទីហ្វុង Yolanda និង ៣) "ការវាយតម្លៃភាពងាយរងគ្រោះដោយមានការចូលរួមនៅក្នុងដែនរងទឹកភ្លៀងបី នៃអាងទន្លេសាប" នៅក្នុងសិក្ខាសាលារៀបចំឡើងនៅ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ប្រទេសកម្ពុជា លើការប្រែប្រួលអាកាសធាតុ៖ បញ្ហាប្រឈម និងឱកាសសម្រាប់ការស្រាវជ្រាវ និងដំណោះស្រាយសមស្រប។

## ផ្នែកអភិបាលកិច្ច

ក្រុមស្រាវជ្រាវបន្តការងារទៅមុខយ៉ាងលឿន ដោយផ្ដោតការយកចិត្តទុកដាក់លើ យុទ្ធសាស្ត្រសម្រាប់ធ្វើកំណែទម្រង់ស្ថាប័នទឹកក្នុងតំបន់ និងការជំនះកំហិតផ្សេងៗដែលរារាំងកំណែទម្រង់វិសហមជ្ឈការ។ លទ្ធផលស្រាវជ្រាវនៃគម្រោង គណនេយ្យភាពសង្គម ដែលបានអនុវត្តចប់សព្វគ្រប់ បានយកទៅចែករំលែកជាមួយសមាជិកអង្គការសង្គមស៊ីវិលកម្ពុជា នៅក្នុង វេទិកា និងបណ្ដាញគំនិតផ្ដួចផ្ដើមអភិបាលកិច្ចក្នុងមូលដ្ឋាន (LOGIN)។

ការសិក្សាស្ដីពី សមត្ថភាពសម្រាប់កំណែទម្រង់វិសហមជ្ឈការនៅកម្ពុជា កំពុងស្ថិតក្នុងដំណាក់កាលបង្ហើយការសិក្សាឯកសារមានស្រាប់ និងការធ្វើផែនការលំអិតសម្រាប់ការចុះសិក្សាដល់កន្លែង។ ការចុះសិក្សាដល់កន្លែងគ្រោងចាប់ផ្ដើមភ្លាម ក្រោយចប់ថ្ងៃឈប់សម្រាកបុណ្យភ្ជុំបិណ្ឌ។

ក្រុមស្រាវជ្រាវគម្រោង លទ្ធភាពសម្រាប់ធ្វើកិច្ចសន្ទនាអំពីអភិបាលកិច្ចទឹកទន្លេមេគង្គ កំពុងរៀបចំរបាយការណ៍លំអិតពីលទ្ធផលទទួលបានក្នុងការចុះសិក្សាដល់កន្លែងនៅខេត្តស្ទឹងត្រែងនៅពាក់កណ្ដាលខែសីហា។ លទ្ធផលទាំងនេះ នឹងយកទៅចែករំលែកក្នុង វេទិកាមហាអនុតំបន់មេគង្គប្រចាំឆ្នាំ២០១៥ ស្ដីពីទឹក ស្បៀងអាហារ និងថាមពល ដែលរៀបចំឡើងដោយ CGIAR នៅថ្ងៃទី ២១-២៣ ខែតុលា ដោយក្រុមស្រាវជ្រាវត្រូវរៀបចំវគ្គមួយស្ដីពី "អភិបាលកិច្ចទឹកទន្លេមេគង្គ៖ បញ្ហាប្រឈម និងឱកាស សម្រាប់បង្កលទ្ធភាពធ្វើកិច្ចសន្ទនាប្រកបដោយទំនួលខុសត្រូវ និងការឆ្លើយតប"។ ក្រុមពិភាក្សារួមមានជំនាញការបួនរូបមកពី វេទិកាអង្គការមិនមែនរដ្ឋាភិបាល សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានគោលនយោបាយទឹក និងក្រសួងធនធានទឹក និងឧតុនិយម។ ដើម្បីកសាងសមត្ថភាពសម្រាប់គម្រោងនេះ នៅខែកញ្ញា អ្នកស្រាវជ្រាវពីររូបបានចូលរួមវគ្គបណ្ដុះបណ្ដាលនៅសាកលវិទ្យាល័យជាតិសិង្ហបុរី (NUS) ដោយអ្នកស្រាវជ្រាវមួយរូប ទទួលបានអាហារូបករណ៍មួយផ្នែកពី មូលនិធិ Temasek សម្រាប់ការចូលរួមក្នុងកម្មវិធី ភាពជាអ្នកដឹកនាំក្នុងការគ្រប់គ្រងទឹក មានរយៈពេលពីរសប្ដាហ៍ នៅសាលាគោលនយោបាយសាធារណៈ Lee Kuan Yew ហើយអ្នកស្រាវជ្រាវមួយរូបទៀត បានចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលរយៈពេលមួយថ្ងៃស្ដីពី ជំនាញចរចានៅវិទ្យាស្ថានគោលនយោបាយទឹក។

## ផ្នែកសុខភាព

កម្មវិធី ការស្រាវជ្រាវដើម្បីកសាងប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញបន្ទាប់ពីបានបញ្ចប់ទំនាស់ (ReBUILD) ដែលជាកម្មវិធីស្រាវជ្រាវរយៈពេល ៧ឆ្នាំ ផ្ដល់មូលនិធិដោយ DFID បានចប់សព្វគ្រប់ តាមការចងក្រងរបាយការណ៍ចុងក្រោយ សម្រាប់អនុគម្រោងបី៖ ហិរញ្ញប្បទានសុខភាព ធនធានមនុស្សសម្រាប់ផ្នែកសុខាភិបាល និងការធ្វើកិច្ចសន្យាផ្ដល់សេវាសុខភាព។

គម្រោងបួនទៀតកំពុងដំណើរការទៅមុខ។ របាយការណ៍ព្រាងស្ដីពី ការបញ្ជូនស្ត្រីត្រូវសម្រាលកូន ក្នុងប្រព័ន្ធសុខាភិបាលនៅកម្ពុជា បានចប់រួចរាល់ និងបញ្ជូនទៅម្ចាស់ជំនួយដើម្បីសុំមតិយោបល់។ ការសិក្សានេះជា គម្រោងរួមគ្នាជាមួយ មជ្ឈមណ្ឌលនូហ្វៀលសម្រាប់ការអភិវឌ្ឍ និងសុខភាពអន្តរជាតិ (Nuffield Centre for International Health and Development) និងសាកលវិទ្យាល័យ Leeds ហើយទទួលជំនួយទ្រទ្រង់ពី ReBUILD Responsive Fund។ គម្រោងបីទៀតដែលនាំឲ្យមានការចងក្រងរបាយការណ៍សំយោគមួយស្ដីពី ពលកម្មកុមារ គឺមាន គម្រោងការលុបបំបាត់ការកេងប្រវ័ញ្ចពលកម្មកុមារ តាមរយៈការអប់រំ និងការលើកស្ទួយជីវភាព (EXCEL), ការស្រាវជ្រាវពីអ្នកដឹកនាំមតិមហាជនលើការផ្ដល់អាហារឲ្យទារកនិងកុមារតូចៗ (IYCF), និងការពិនិត្យផ្ទៀងផ្ទាត់លើលទ្ធផលផ្នែកអនាម័យ ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃការកែលំអអនាម័យនៅទីជនបទ។ គម្រោងទាំងបីនេះ ស្ថិតក្នុងដំណាក់កាលវិភាគទិន្នន័យ និងចងក្រងរបាយការណ៍ ហើយរំពឹងថានឹងចប់សព្វគ្រប់នៅចុងឆ្នាំ២០១៥។


## Cambodia Development Review—2015 Subscription Rates

**Domestic subscription (individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic subscription (discount price for bulk orders—five copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❒Mr ❒Ms ❒Dr ❒Other ..........

First name: .......... Last name: .......... Position: ..........

Organisation / Company: ..........

Address (CCC Box if applicable): ..........

City / Province: .......... Country: ..........

Telephone: .......... Fax: ..........

e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Unit at CDRI if your contact details change.

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

**៨ កក្កដា៖** លោកនាយកប្រតិបត្តិវិទ្យាស្ថាន CDRI បានចូលរួមក្នុងការពិភាក្សាមួយស្តីពី "បញ្ហាប្រឈមខាងស្ថាប័ន និងឱកាសសម្រាប់ដំណាក់កាលបន្ទាប់នៃ GMS" នៅក្នុងវេទិកាមេគង្គឆ្នាំ២០១៥ ស្តីពី "ទំនើបកម្ម GMS ឆ្ពោះទៅរកដំណាក់កាលបន្ទាប់ក្រោយការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥" ដែលរៀបចំឡើងដោយវិទ្យាស្ថានមេគង្គ នៅខេត្តខនកែន ប្រទេសថៃ។ ឯកឧត្តម បណ្ឌិត សុក ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាលវិទ្យាស្ថាន CDRI ជាវាគ្មិនសំខាន់មួយរូបនៅក្នុងវេទិកានោះ។ ព្រឹត្តិការណ៍នេះជាឱកាសដ៏ល្អមួយសម្រាប់ឲ្យវិទ្យាស្ថាន CDRI កសាងទំនាក់ទំនងជាមួយក្រុមផ្តល់គំនិតក្នុងតំបន់មេគង្គ និងជំរុញកម្មវិធី GMS Net ស្តីពី "ការបង្កើនឱកាសការងារសម្រាប់យុវជនពលករមានជំនាញទាប និងពលករជានារីភេទ នៅតំបន់មេគង្គ" ដែលទទួលបានការទ្រទ្រង់ពី មជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា។

**១០ កក្កដា៖** វិទ្យាស្ថាន CDRI បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារលើកទី១២ នៃ វេទិកាស្រាវជ្រាវអភិវឌ្ឍន៍ (DRF) ដំណាក់កាលទី២។ កិច្ចប្រជុំនេះ សំដៅប្រមូលមតិយោបល់ ធាតុចូល និងសំណូមពរ សម្រាប់កម្មវិធីសន្និសីទ DRF លើកទី៨ ក្នុងឆ្នាំ២០១៥ និងពិភាក្សាពីសំណើ និងកិច្ចសហការជាដៃគូសម្រាប់ DRF ដំណាក់កាលទី៣។

**២១-២២ កក្កដា៖** លោកនាយកប្រតិបត្តិវិទ្យាស្ថាន CDRI បានចូលរួមជាវាគ្មិនគន្លឹះមួយរូបនៅក្នុង សន្និសីទអន្តរជាតិស្តីពី "កិច្ចការសង្គមកិច្ចជាលក្ខណៈវិជ្ជាជីវៈនៅ តំបន់អាស៊ីអាគ្នេយ៍៖ ការអប់រំ និងគុណសម្បត្តិ" ដែលរៀបចំឡើងដោយដេប៉ាតឺម៉ង់កិច្ចការសង្គមកិច្ច នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) នៅសណ្ឋាគារសាន់វេ នៅរាជធានីភ្នំពេញ។ លោកបានផ្តល់បទបង្ហាញស្តីពី "យុទ្ធសាស្ត្ររៀនសូត្ររបស់មនុស្សពេញវ័យសម្រាប់សាកលវិទ្យាល័យនៅកម្ពុជា"។ សន្និសីទនេះ ជាឱកាសដ៏ល្អមួយសម្រាប់ការកសាងបណ្តាញ និងស្វែងរកដៃគូសហការសំខាន់ៗដែលអាចចូលរួមចំណែកក្នុង កម្មវិធីស្រាវជ្រាវ ផ្នែកអប់រំរបស់ CDRI។

**២១ សីហា៖** លោកនាយកប្រតិបត្តិ បានចូលរួមក្នុងកិច្ចប្រជុំតុមូលផ្នែកគោលនយោបាយមួយ ស្តីពី "តើធ្វើយ៉ាងណាដើម្បីជំរុញវប្បធម៌ស្រាវជ្រាវនៅកម្ពុជា? ការយល់ឃើញពីកម្មវិធីសិក្សា និងបរិយាកាសអំណោយផលនៅគ្រឹះស្ថានឧត្តមសិក្សា" រៀបចំឡើងដោយ RUPP នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ (CKCC)។ កិច្ចប្រជុំតុមូលនេះ ជាវេទិកាដ៏វិសេសមួយសម្រាប់ឲ្យ CDRI ចូលរួមក្នុងកិច្ចសន្ទនាដ៏មានខ្លឹមសារជាមួយថ្នាក់ដឹកនាំកំពូលៗផ្នែកសិក្សាស្រាវជ្រាវ និងទទួលបាននូវការទិតៀនស្ថាបនា និងធាតុចូលដែលមានប្រយោជន៍សម្រាប់ជួយតម្រង់ទិសគម្រោងស្រាវជ្រាវរបស់វិទ្យាស្ថាន។

**២៦ សីហា៖** វិទ្យាស្ថាន CDRI បានរៀបចំកិច្ចប្រជុំតុមូលផ្នែកគោលនយោបាយ នៃវេទិកា DRF ស្តីពី "លក្ខណៈវិជ្ជាជីវៈក្នុងផ្នែកវេជ្ជសាស្ត្រនៅកម្ពុជា៖ បញ្ហាចោទ និងមធ្យោបាយឈានទៅមុខ" នៅសណ្ឋាគារភ្នំពេញ ដោយមានការចូលរួមពី ក្រុមប្រឹក្សាផ្នែកថែទាំសុខភាពចម្បងៗ (គ្រូពេទ្យ ឱសថការី គិលានុបដ្ឋាក ឆ្មប) មន្ត្រីជាន់ខ្ពស់មកពីក្រសួងសុខាភិបាល និងតំណាងមកពីសាលាវេជ្ជសាស្ត្រនានា និងវិស័យឯកជន (ក្រុមហ៊ុនផលិតឱសថ)។ កិច្ចប្រជុំនេះបានកំណត់ឃើញ ប្រធានបទជាច្រើនខាងផ្នែកគោលនយោបាយ និងការស្រាវជ្រាវសម្រាប់ការធ្វើសកម្មភាពទាក់ទងនឹងលក្ខណៈវិជ្ជាជីវៈក្នុងការថែទាំសុខភាព។

**២៨ សីហា៖** នៅក្នុងកិច្ចប្រជុំពាក់កណ្តាលឆ្នាំរបស់ខ្លួន ក្រុមប្រឹក្សាភិបាល CDRI បានថ្លែងអំណរគុណដល់លោក អ៊ឹង ស៊ានលី ចំពោះការចូលរួមចំណែកជួយដល់វិទ្យាស្ថាន។ លោកបានលាឈប់ពីតំណែងជានាយកផ្នែកប្រតិបត្តិការនៅខែកញ្ញា។ លោកនាយកប្រតិបត្តិ បានបង្ហាញខ្លួន អ្នកគ្រប់គ្រងជាន់ខ្ពស់ថ្មីពីររូបគឺ ១) បណ្ឌិត ថែម ផល្លា ជាប្រធានស្តីទីផ្នែកស្រាវជ្រាវ៖ លោកមានឈ្មោះល្បីសុះសាយនៅប្រទេសកម្ពុជា និងក្នុងតំបន់ តាមការស្រាវជ្រាវរបស់លោក ស្តីពី ការគ្រប់គ្រងធនធានទឹក និងការប្រែប្រួលអាកាសធាតុ និង ២) បណ្ឌិត អ៊ុច ច័ន្ទតារ៉ានី អ្នកគ្រប់គ្រង

តទៅទំព័រ ១៧

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា
ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ឆ្នាំទី១៩ លេខ៣ ខែកញ្ញា ឆ្នាំ២០១៥

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវការវាយតម្លៃឯករាជ្យពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីមិត្តអ្នកអាន។ លិខិត ត្រូវមានចុះហត្ថលេខាអាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
(៨៥៥ ២៣) ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយ: វបសអ
គ្រប់គ្រងកែសម្រួល: យូ សិទ្ធិរិទ្ធ
កែសម្រួលផលិតកម្ម: អ៊ុំ ចាន់ថា ខេង សេង និង ម៉េន ច័ន្ទធីតា
សហគ្រាសបោះពុម្ព Invent Cambodia, រូបភាពទំព័រមុខ: ជួន វណ្ណលី អ្នកគ្រូនៅសាលាបឋមសិក្សា

© រក្សាសិទ្ធិ ២០១៥ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh